# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៤-០១-២០១២ -ព្រះរាជក្រម នស/រកម/០១១២/០០៥ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម ៧០៣


### ២~ព្រះរាជក្រឹត្យ


១៣-០១-២០១២-ព្រះរាជក្រឹត្យ នស/រកត/០១១២/០២២ ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ ចំនួន ០២ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងស្ថាប័ន ដោយមូលហេតុមរណភាព ៧៥៩

១៣-០១-២០១២-ព្រះរាជក្រឹត្យ នស/រកត/០១១២/០២៤ ស្តីពី ការដំឡើងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការ ចំនួន ០៣ រូប ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច ៧៦១

១៣-០១-២០១២-ព្រះរាជក្រឹត្យ នស/រកត/០១១២/០២៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ នាយទាហានជាន់ខ្ពស់ នៃ កងយោធពលខេមរភូមិន្ទ និង សប្បុរសជន ចំនួន ២៦៧ រូប ៧៦៣

១៣-០១-២០១២-ព្រះរាជក្រឹត្យ នស/រកត/០១១២/០៣៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ នាយទាហានជាន់ខ្ពស់ នៃ កងយោធពលខេមរភូមិន្ទ និង សប្បុរសជន ចំនួន ១៦ រូប ៧៧៣


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


២៦-០១-២០១២-អនុក្រឹត្យលេខ ១៥ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៧៧៥

២៦-០១-២០១២-អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៧៧៧

២៦-០១-២០១២-អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្តីពី ការធ្វើអនុបយោគផ្ទៃដី ទំហំ ៨.២០០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកគូលេន និង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ៧៧៩

០២-៦-២០១១ -អនុក្រឹត្យលេខ ៦៣៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៨២

២៤-០១-២០១២ -អនុក្រឹត្យលេខ ៩៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៣

២៤-០១-២០១២ -អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៨៤

២៥-០១-២០១២ -អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៨៦

២៥-០១-២០១២ -អនុក្រឹត្យលេខ ៩៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៧៨៨

២៥-០១-២០១២ -អនុក្រឹត្យលេខ ៩៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៩

២៦-០១-២០១២ -អនុក្រឹត្យលេខ ១០០ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៩០

២៦-០១-២០១២ -អនុក្រឹត្យលេខ ១០១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៩២

## ២-សេចក្តីសម្រេច

៣០-០១-២០១២ -សេចក្តីសម្រេចលេខ ០៨ សសរ ស្តីពី ការតែងតាំងទីប្រឹក្សាបច្ចេកទេសរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៧៩៣

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៤-០១-២០១២ -ប្រកាសលេខ ០៦៨ ឧរថ.ឧតស.ប្រក ស្តីពី ការកែសម្រួលនីតិវិធីនៃការចុះបញ្ជីផលិតផល (ច.ប.ផ) ៧៩៤

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣០-១១-២០១០-លិខិតបញ្ជាក់លេខ ៥៤៤៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលឌ្យូ អ៊ិនវេសមេនអិលធីឌី** ៨០៣

៣០-១១-២០១០-លិខិតបញ្ជាក់លេខ ៥៤៤៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម.ខេ.អ.អ៊ិមផត អិចផត** ៨០៥

០១-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមរា អេឡិតទ្រិត អ៊ីមផត អិចផត** ៨០៧

០១-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៤៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ី.អេស.ធី. យូនៀន** ៨០៩

០១-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៥០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយ ១ អ៊ិនហ្វូ ខម** ៨១១

# ព្រះរាជក្រម

នស/រកម/០១១២/០០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងថ្នាំកសិកម្ម

# និងជីកសិកម្ម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណង :

- គាំទ្រគោលនយោបាយជំរុញការប្រើប្រាស់សក្តានុពលភាពនៃវិស័យកសិកម្មឲ្យមានប្រសិទ្ធិភាពខ្ពស់ដើម្បីអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ចជាតិ
- ធានាការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ព្រមទាំងមានសង្គតិភាពជាមួយនឹងបមាណីយអន្តរជាតិ
- លើកកម្ពស់ការយល់ដឹងជាសាធារណៈ លើការអនុវត្តការតម្រូវបមាណីយសម្រាប់ថ្នាំកសិកម្ម និងជីកសិកម្ម នៅក្នុងគ្រប់សកម្មភាពពាក់ព័ន្ធនឹងផលិតផលនេះ
- កាត់បន្ថយហានិភ័យដែលបង្កដោយការប្រើប្រាស់ថ្នាំកសិកម្ម និងជីកសិកម្ម ដើម្បីផលប្រយោជន៍របស់កសិករ និងប្រជាពលរដ្ឋទូទាំងប្រទេស ដោយធានាបាននូវសន្តិសុខស្បៀង សុវត្ថិភាពស្បៀង សុខភាពសាធារណៈ និងនិរន្តរភាពនៃបរិស្ថាន ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រង និងការតម្រូវបមាណីយលើ :

- ថ្នាំកសិកម្មនិងជីកសិកម្មគ្រប់ប្រភេទ វត្ថុធាតុដើម ឬសារធាតុសកម្ម និងសមាសធាតុផ្សេងទៀតនៃថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ ដែលប្រើប្រាស់ជាធាតុចូលនៅក្នុងផលិតកម្មកសិកម្ម
- គ្រប់សកម្មភាពរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលជាពាណិជ្ជករ អ្នកលាយផ្សំផលិតផល សេវាករកម្ចាត់សមាសភាពចង្រៃ អ្នកផ្សាយពាណិជ្ជកម្ម អ្នកធ្វើអំណោយ និងអ្នកប្រើប្រាស់ថ្នាំកសិកម្មនិងជីកសិកម្មគ្រប់ប្រភេទ ។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ពន្ធនៃច្បាប់នេះ:

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ២
# សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់អង្គភាពមានសមត្ថកិច្ចដើម្បីបំពេញបេសកកម្មដូចខាងក្រោម :

- ធានាការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មប្រកបដោយប្រសិទ្ធភាព ដោយអនុលោមតាមគោលនយោបាយវិស័យកសិកម្ម
- សិក្សា និងរៀបចំក្របខ័ណ្ឌគតិយុត្តស្តីពីការតម្រូវបមាណីយ នីតិវិធីមុនការចុះបញ្ជី និងក្រោយការចុះបញ្ជីសម្រាប់ថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ
- សិក្សា វាយតម្លៃលើការបំពេញការតម្រូវបមាណីយសម្រាប់សំណើសុំការចុះបញ្ជីថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ
- វិភាគផ្ទៀងផ្ទាត់សមាសធាតុនៃថ្នាំកសិកម្ម និងបមាណីយធានានៃជីកសិកម្ម នៅមន្ទីរពិសោធន៍ និងធ្វើការសាកល្បងជីវប្រសិទ្ធភាពលើទីវាលពិសោធន៍ សម្រាប់ការវាយតម្លៃនៅមុន និងក្រោយការចុះបញ្ជី
- អនុវត្តការចុះបញ្ជី ការផ្តល់លិខិតអនុញ្ញាត សម្រាប់សកម្មភាពពាក់ព័ន្ធនឹងថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ និងការប្រមូលកម្រៃសេវាកម្មសម្រាប់សកម្មភាពទាំងនេះ ដែលតម្រូវដោយច្បាប់នេះ
- អនុវត្តកម្មវិធីសិក្សាស្រាវជ្រាវលើប្រភេទថ្នាំកសិកម្ម និងជីកសិកម្ម និងផលប៉ះពាល់នៅក្នុងផលិតកម្មកសិកម្ម
- អនុវត្តកម្មវិធីអប់រំផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ និងកម្មវិធីបណ្តុះបណ្តាលស្តីពីថ្នាំកសិកម្ម និងជីកសិកម្ម
- សហការ និងសម្របសម្រួលជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍនានាក្នុងក្របខ័ណ្ឌនៃការពង្រីកព័ត៌មានស្តីពីការយល់ដឹងជាសាធារណៈ និងការ[illegible]អនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព

- តាមដាន ត្រួតពិនិត្យ និងចាត់វិធានការជំរុញការអនុវត្តច្បាប់ លើរាល់សកម្មភាពគ្រប់គ្រង និងការអនុវត្តការតម្រូវបមាណីយសម្រាប់ថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ

- អនុវត្តកិច្ចសហប្រតិបត្តិការអន្តរជាតិ និងបំពេញតួនាទីជាស្ថាប័នបង្គោលថ្នាក់ជាតិទទួលបន្ទុកដឹកនាំ និងអនុវត្តភារកិច្ចពាក់ព័ន្ធនឹងអនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិស្តីពីថ្នាំកសិកម្ម និងសារធាតុគីមីកសិកម្ម

- បំពេញភារកិច្ចផ្សេងទៀត ក្នុងការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ក្រោមវិសាលភាពនៃច្បាប់នេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រងថ្នាំកសិកម្ម

### ផ្នែកទី ១
### ការចុះបញ្ជីថ្នាំកសិកម្ម និងការតម្រូវបមាណីយ

**មាត្រា ៧.-**

ថ្នាំកសិកម្មគ្រប់ប្រភេទអាចធ្វើពាណិជ្ជកម្ម ឬធ្វើការលាយផ្សំបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា លុះត្រាតែថ្នាំកសិកម្មនោះត្រូវបានយល់ព្រមលើការចុះបញ្ជីតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូលនាំចេញ ឬធ្វើការលាយផ្សំថ្នាំកសិកម្មគ្រប់ប្រភេទ ក្នុងគោលបំណងធ្វើពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំការចុះបញ្ជីប្រភេទថ្នាំកសិកម្មនោះជាមុន នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលអាចស្នើសុំការចុះបញ្ជីក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ នូវថ្នាំកសិកម្មទាំងឡាយដែល :

១- មិនស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់ក្នុងបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ។

២- ធ្លាប់បានទទួលការចុះបញ្ជី ប៉ុន្តែត្រូវបានផ្លាស់ប្តូរសមាសធាតុ ។

៣- ធ្លាប់បានទទួលការចុះបញ្ជី ប៉ុន្តែមានការកែប្រែលក្ខខណ្ឌ ទិន្នន័យ ឬព័ត៌មានបច្ចេកទេស ។

៤- ធ្លាប់បានទទួលការចុះបញ្ជី ប៉ុន្តែមានប្រភពលាយផ្សំថ្មី ។

**មាត្រា ៩.-**

ថ្នាំកសិកម្មគ្រប់ប្រភេទដែលមានក្នុងបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានសម្គាល់ដោយលេខអត្តសញ្ញាណ និងត្រូវបានចាត់ថ្នាក់តាមកម្រិតភាពពុល ស្របតាមបមាណីយនៃអង្គការសុខភាពពិភពលោក ឬបមាណីយអន្តរជាតិដែលពាក់ព័ន្ធ។

បញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចសម្រេចបញ្ចូលបន្ថែម កែសម្រួល ឬលុបចោលប្រភេទថ្នាំកសិកម្ម ឬសារធាតុសកម្មនៃថ្នាំកសិកម្មណាមួយនៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមការចាំបាច់ ដោយផ្អែកលើលទ្ធផលស្រាវជ្រាវ ឬដោយអនុលោមតាមការតម្រូវនៃអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ។

**មាត្រា ១០.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម មានកាតព្វកិច្ចបំពេញតាមការតម្រូវបមាណីយ ដោយត្រូវផ្តល់ព័ត៌មានពេញលេញ និងត្រឹមត្រូវសម្រាប់ការពិនិត្យនិងការវាយតម្លៃ ។

ឯកសារប្រភពដើមនៃព្រឹត្តិបត្រព័ត៌មានសុវត្ថិភាពនៃថ្នាំកសិកម្ម ព័ត៌មានស្តីពីសមាសធាតុ វិធីសាស្ត្រវិភាគ ទិន្នន័យជីវប្រសិទ្ធភាព និងព័ត៌មានបច្ចេកទេសផ្សេងទៀត គឺជាការតម្រូវបមាណីយចាំបាច់ដែលត្រូវយកមកភ្ជាប់ជាមួយនឹងសំណុំបែបបទស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម ។

**មាត្រា ១១.-**

ការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវជានាឲ្យមានព័ត៌មាន និងទិន្នន័យដូចខាងក្រោម :

- អត្តសញ្ញាណរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជី អត្តសញ្ញាណថ្នាំកសិកម្ម និងដំណើរការលាយផ្សំ
- ទិន្នន័យយថាប្រភេទនៃថ្នាំកសិកម្ម សមាសធាតុ សារធាតុសកម្ម វិធីសាស្ត្រវិភាគ លក្ខណៈរូបនិងគីមីនៃសារធាតុសកម្ម និងទិន្នន័យផ្សេងទៀតនៃសមាសធាតុថ្នាំកសិកម្ម
- ទិន្នន័យជីវប្រសិទ្ធភាពចេញពីប្រទេសប្រភពដើម និងរបាយការណ៍ពីការសាកល្បងជីវប្រសិទ្ធិភាពលើទីវាលពិសោធន៍ តាមប្រភេទដំណាំ និងតំបន់សាកល្បង
- ទិន្នន័យភាពពុលនៃថ្នាំកសិកម្ម
- ទិន្នន័យសំណល់នៃថ្នាំកសិកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- សុវត្ថិភាពចំពោះមនុស្ស សត្វ
- សុវត្ថិភាពចំពោះបរិស្ថាន
- ពាណិជ្ជកម្ម ការប្រើប្រាស់ និងការបោះចោលសំណល់នៃការប្រើប្រាស់
- សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ។

**មាត្រា ១២.-**

ថ្នាំកសិកម្មគ្រប់ប្រភេទដែលជាកម្មវត្ថុនៃការសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវឆ្លងកាត់ការវិភាគ ការសាកល្បងជីវប្រសិទ្ធភាព និងការវាយតម្លៃលើហានិភ័យសំណាកថ្នាំកសិកម្មនោះដោយអនុលោមតាមការតម្រូវបមាណីយ ។

**មាត្រា ១៣.-**

ការវិភាគសំណាកថ្នាំកសិកម្ម ត្រូវអនុវត្តចំពោះសារធាតុសកម្មនីមួយៗនៃថ្នាំកសិកម្ម និងត្រូវប្រព្រឹត្តទៅនៅមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលមានការទទួលស្គាល់ ដូចមានចែងក្នុងមាត្រា ៨៧ នៃច្បាប់នេះ ។

គោលការណ៍ណែនាំសម្រាប់សំណាកថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១៤.-**

ការពិសោធសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម ត្រូវអនុវត្តនៅស្ថានីយពិសោធន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬត្រូវអនុវត្តដោយអ្នកស្រាវជ្រាវដែលមានការទទួលស្គាល់ដូចមានចែងក្នុងមាត្រា ៨៧ នៃច្បាប់នេះ ។

ពិធីសារបច្ចេកទេសសាកល្បងជីវប្រសិទ្ធភាពនៃថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១៥.-**

វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្មដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់តាមប្រភេទបញ្ជិកាដូចខាងក្រោម :

១- បញ្ជិកាពេញលេញ ។

២- បញ្ជិកាបណ្តោះអាសន្ន ឬបញ្ជិកាស្ថិតក្នុងលក្ខខណ្ឌ ។



**មាត្រា ១៦.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបដិសេធសំណើសុំការចុះបញ្ជីថ្នាំកសិកម្មដោយផ្អែកតាមលក្ខណវិនិច្ឆ័យណាមួយដូចខាងក្រោម ៈ

១- ព័ត៌មាន និងទិន្នន័យដែលភ្ជាប់ក្នុងសំណុំបែបបទស្នើសុំការចុះបញ្ជីមានភាពមិនពិត ។

២- ប្រភេទថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជី មានគ្រោះថ្នាក់ខ្ពស់ចំពោះសុខភាពសាធារណៈ ឬមានហានិភ័យខ្ពស់ជាងផលប្រយោជន៍នៃការប្រើប្រាស់ប្រភេទថ្នាំកសិកម្មនោះ ។

៣- ប្រភេទថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជី គឺជាផលិតផលបំពុលរុក្ខជាតិដែលមិនអាចទូទាត់ការបង់ខាតចំពោះទិន្នផលដំណាំ ។

៤- ប្រសិទ្ធភាពនៃថ្នាំកសិកម្មមានកម្រិតទាបជាងបមាណីយដែលបានអះអាងក្នុងសំណើសុំការចុះបញ្ជី ។

៥- ប្រភេទថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជី មានសំណល់ដែលមិនងាយបំបែកជាតុបាននៅក្នុងដំណាំ និងនៅក្នុងបរិស្ថាន ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុគ្រោះចំពោះការតម្រូវបមាណីយលើការចុះបញ្ជីថ្នាំកសិកម្ម សម្រាប់តម្រូវការសាធារណៈជាក់លាក់ណាមួយ សម្រាប់ប្រើក្នុងវិស័យសិក្សាធិការ សុខភាពសាធារណៈ និងការស្រាវជ្រាវ ឬសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មផ្សេងទៀតតាមការចាំបាច់ ។

**មាត្រា ១៧.-**

វិញ្ញាបនបត្របញ្ជាក់បញ្ជិកាពេញលេញថ្នាំកសិកម្ម ត្រូវមានសុពលភាពរយៈពេល ០៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកានីមួយៗ លើកលែងតែមានការដកហូតនៅមុនពេលផុតសុពលភាព ។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់កាប់បញ្ជិកាពេញលេញថ្នាំកសិកម្មអាចស្នើសុំការចុះបញ្ជីជាថ្មី ដោយត្រូវភ្ជាប់សំណុំបែបបទ និងសម្រង់ព័ត៌មានតាមនីតិវិធីនៃច្បាប់នេះ ។

បញ្ជិកាបណ្ដោះអាសន្នថ្នាំកសិកម្មអាចផ្ទេរទៅជាបញ្ជិកាពេញលេញក្នុងរយៈពេល ០១ (មួយ) ឆ្នាំ នៅពេលដែលបណ្ដាលក្ខខណ្ឌ និងការតម្រូវទាំងឡាយត្រូវបានបំពេញគ្រប់គ្រាន់ ។ ក្នុងករណីមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ បញ្ជិកាបណ្ដោះអាសន្ននោះត្រូវទុកជានិរាករណ៍ ។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់កាប់បញ្ជិកាបណ្ដោះអាសន្នថ្នាំកសិកម្ម មិនអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មប្រភេទថ្នាំកសិកម្មនោះបានឡើយ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ១៨.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តម្រូវឲ្យអ្នកកាន់កាប់បញ្ជិកាថ្នាំកសិកម្មពិនិត្យឡើងវិញ និងស្នើសុំការចុះបញ្ជីជាថ្មីក្នុងករណីដែលទិន្នន័យប្រើប្រាស់លើទីវាលពិសោធន៍បង្ហាញផលប៉ះពាល់ពាក់ព័ន្ធនឹងភាពពុល ឬសំណល់ថ្នាំកសិកម្មលើសពីកម្រិតអនុគ្រោះ។

ចំពោះរាល់ថ្នាំកសិកម្មទាំងឡាយណាដែលផុតសុពលភាពបញ្ជិកាដោយគ្មានការស្នើសុំការចុះបញ្ជីជាថ្មី ត្រូវបញ្ឈប់ការផ្គត់ផ្គង់ចែកចាយ ហើយតម្រូវឲ្យប្រមូលមកវិញក្រោមបន្ទុកសិទ្ធិវន្តលើបញ្ជិកានោះ ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទផុតសុពលភាពបញ្ជិកា ។

**មាត្រា ១៩.-**

រាល់ទិន្នន័យដែលបានភ្ជាប់ និងអះអាងសម្រាប់ការចុះបញ្ជីថ្នាំកសិកម្មតាមរយៈការសាកល្បងលើទីវាលពិសោធន៍ ត្រូវបានការពារសិទ្ធិលើទិន្នន័យក្នុងរយៈពេល ០៨ (ប្រាំបី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកាតាមការស្នើសុំ ។

**មាត្រា ២០.-**

អ្នកកាន់កាប់បញ្ជិកាថ្នាំកសិកម្មមានកាតព្វកិច្ចធ្វើរបាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីផលប៉ះពាល់ដែលកើតឡើងពីការប្រើប្រាស់ផលិតផលថ្នាំកសិកម្ម តាមការណែនាំក្នុងស្លាកសញ្ញាព័ត៌មានដែលបានអះអាងនៅពេលស្នើសុំការចុះបញ្ជី ។

របាយការណ៍ត្រូវកំណត់អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ ទីកន្លែងប្រើប្រាស់ ប្រភេទថ្នាំកសិកម្ម និងកម្រិតប្រើប្រាស់ សេចក្តីសន្និដ្ឋានលើផលប៉ះពាល់ និងលទ្ធផលចុងក្រោយ ។

**មាត្រា ២១.-**

រាល់នីតិវិធីសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម ត្រូវមានសង្គតិភាពជាមួយនឹងនីតិវិធីសម្រាប់ការចុះបញ្ជីថ្នាំកសិកម្មក្នុងក្របខ័ណ្ឌអន្តរជាតិ ឬតំបន់ ។

នីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី ២
## ស្លាកសញ្ញាព័ត៌មាន និងព្រឹត្តិបត្រព័ត៌មានសុវត្ថិភាព

**មាត្រា ២២.-**

គ្រប់ស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្មដែលប្រើប្រាស់លើសំបកវេចខ្ចប់ថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រាល់សំបកវេចខ្ចប់នៃថ្នាំកសិកម្មគ្រប់ប្រភេទដែលចេញពីប្រភពដើមលាយផ្សំ វេចខ្ចប់ជាថ្មី ឬ នាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជានាស្លាកសញ្ញាព័ត៌មានដែលបង្ហាញអត្ថបទសង្ខេបដូចខាងក្រោម ៖

- ឈ្មោះ និងអាសយដ្ឋានរបស់ក្រុមហ៊ុនកាន់កាប់បញ្ជិកា
- ឈ្មោះទូទៅ ឈ្មោះពាណិជ្ជកម្មនៃថ្នាំកសិកម្ម និងពាណិជ្ជសញ្ញា
- អត្ថបទសង្ខេបស្តីពីសមាសធាតុ រួមមានគ្រប់សារធាតុសកម្ម តាមកំហាប់ ឬអត្រា និងអត្តសញ្ញាណគីមីរបស់វា និងស្តីពីចំណាត់ថ្នាក់ប្រើប្រាស់ និងចំណាត់ថ្នាក់គ្រោះថ្នាក់នៃថ្នាំកសិកម្ម
- លេខបញ្ជិកាដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រុមហ៊ុន និងប្រទេសប្រភពដើមលាយផ្សំ ឬនាំចេញ
- ចំណុះសុទ្ធសាជនៃថ្នាំកសិកម្មនៅក្នុងសំបកវេចខ្ចប់
- បទណែនាំបច្ចេកទេសពាក់ព័ន្ធនឹងរបៀបប្រើប្រាស់ ប្រភេទដំណាំ និងសមាសភាពចង្រៃដែលត្រូវប្រើ កម្រិតប្រើប្រាស់ ពេលវេលាប្រើប្រាស់ និងរយៈពេលបញ្ឈប់ការប្រើប្រាស់
- បទហាមប្រាម និងបទប្រុងប្រយ័ត្ន បញ្ជាក់ពីហេតុសញ្ញាក្នុងភាពពុល វិធានសុវត្ថិភាពក្នុងការប្រើប្រាស់ វិធានការការពារសុខភាព ការសង្គ្រោះបឋម និងព័ត៌មានសម្រាប់ពេទ្យសង្គ្រោះ
- និមិត្តសញ្ញាបង្ការគ្រោះថ្នាក់ និងរូបសញ្ញាព្រមានចំពោះថ្នាំកសិកម្មដែលមានភាពពុលខ្លាំង
- សេចក្តីណែនាំពាក់ព័ន្ធនឹងការបំបាត់ភាពពុល និងវិធានសុវត្ថិភាពក្នុងការបោះចោលសំណល់ និងសំបកវេចខ្ចប់ដែលប្រើរួច
- លេខរៀងឡូត៍ កាលបរិច្ឆេទផលិត និងកាលបរិច្ឆេទផុតកំណត់ប្រើប្រាស់
- ព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២៣.-**

រាល់ស្លាកសញ្ញាព័ត៌មានរបស់ថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវតែមានជាភាសាខ្មែរ និងត្រូវភ្ជាប់មកជាមួយ ឬបោះពុម្ពនៅលើផ្ទៃនៃសំបកវេចខ្ចប់ក្នុងលក្ខណៈដែលព័ត៌មានទាំងអស់នៃស្លាកសញ្ញា អាចមើលឃើញ អានបាន ងាយយល់ និងមិនងាយលុប ។

រាល់ស្លាកសញ្ញាព័ត៌មានរបស់ថ្នាំកសិកម្មទាំងឡាយដែលដាក់តាំងលក់ ឬធ្វើសន្និធិសម្រាប់លក់ត្រូវជៀសវាងការដាច់រហែក លុប ឬខូចខាត ទោះជាទាំងមូលក្តី ដោយផ្នែកក្តីដែលធ្វើឲ្យខូចខាតដល់បទបញ្ញាពាក់ព័ន្ធជាធរមាន ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ២៤.-**

គ្មានស្លាកសញ្ញាព័ត៌មានណាមួយនៃថ្នាំកសិកម្មដែលប្រើអត្ថបទអះអាងថាគ្មានគ្រោះថ្នាក់ ឬមិនពុលឡើយ ។ ផ្នែកនៃស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្មដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់នៃភាពពុល ត្រូវបង្ហាញព័ត៌មានចាំបាច់តាមលំដាប់លំដោយនូវ : បទហាមប្រាម បទប្រុងប្រយ័ត្ន រូបសញ្ញា និងនិមិត្តសញ្ញាព្រមានចំពោះភាពពុល ការសង្គ្រោះបឋម និងព័ត៌មានសម្រាប់ពេទ្យសង្គ្រោះ ។

**មាត្រា ២៥.-**

បមាណីយនៃស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្ម ត្រូវបានកំណត់ដោយអនុលោមតាមប្រព័ន្ធនៃការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមីជាសាកល ។

គោលការណ៍ណែនាំសម្រាប់ស្លាកសញ្ញាព័ត៌មាន និងគំរូស្លាកសញ្ញាព័ត៌មាននៃថ្នាំកសិកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២៦.-**

ព្រឹត្តិបត្រព័ត៌មានសុវត្ថិភាពនៃថ្នាំកសិកម្ម ត្រូវធ្វើជាភាសាខ្មែរ និងត្រូវផ្តល់ជាចាំបាច់នៅពេលស្នើសុំការចុះបញ្ជីដែលជានាព័ត៌មាន និងទិន្នន័យប្រភពដើមនៃប្រទេសផលិត ឬនាំចេញ និងត្រូវបានប្រើប្រាស់សម្រាប់ស្លាកសញ្ញាព័ត៌មាននៃថ្នាំកសិកម្មនោះ ។

ក្រុមហ៊ុននៃប្រទេសដើមដែលនាំចេញថ្នាំកសិកម្ម មានកាតព្វកិច្ចផ្តល់ ឬភ្ជាប់ព្រឹត្តិបត្រព័ត៌មានសុវត្ថិភាពសម្រាប់ក្រុមហ៊ុនដែលនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជាជាចាំបាច់ ដោយអនុលោមតាមការតម្រូវនៃអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ។

## ផ្នែកទី ៣
## ការគ្រប់គ្រងថ្នាំកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម

**មាត្រា ២៧.-**

បន្ថែមលើបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការគ្រប់គ្រងពាណិជ្ជកម្ម គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមានសិទ្ធិធ្វើពាណិជ្ជកម្មថ្នាំកសិកម្មគ្រប់ប្រភេទដែលមានប្រភពចេញពីប្រតិបត្តិការ រួមមាន ការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការធ្វើសេវាកម្មកម្ចាត់សមាសភាពចង្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានលិខិតអនុញ្ញាតឡើយ ហើយរូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយ និងវិធានសុវត្ថិភាពដែលតម្រូវដោយបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL

**មាត្រា ២៨.-**

ការគ្រប់គ្រងថ្នាំកសិកម្មលំនៅឋាន និងថ្នាំកសិកម្មសម្រាប់សុខភាពសាធារណៈ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## អនុផ្នែកទី ១
## ការនាំចូលនាំចេញថ្នាំកសិកម្ម

**មាត្រា ២៩.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូលនាំចេញថ្នាំកសិកម្ម ត្រូវមានលិខិតអនុញ្ញាតដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងរាល់ប្រតិបត្តិការនៃការនាំចូលនាំចេញថ្នាំកសិកម្ម អ្នកនាំចូលនាំចេញត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម :

- ថ្នាំកសិកម្មត្រូវបានយល់ព្រមលើការចុះបញ្ជីរួចហើយ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ត្រូវអនុវត្តបមាណីយសម្រាប់សំបកវេចខ្ចប់ ស្លាកសញ្ញាព័ត៌មាន ឬបរិយាយបណ្ណសម្រាប់ការណែនាំជាភាសាខ្មែរ ដែលត្រូវបានយល់ព្រមចុះបញ្ជី
- បញ្ជីឈ្មោះថ្នាំកសិកម្មដែលស្នើសុំនាំចូលនាំចេញ ត្រូវសម្គាល់ដោយលេខកូដប្រព័ន្ធសុខដុមនីយកម្មគយ
- ត្រូវអនុវត្តវិធានសុវត្ថិភាពក្នុងប្រតិបត្តិការនាំចូលនាំចេញថ្នាំកសិកម្មដែលតម្រូវដោយច្បាប់នេះ
- ត្រូវមានកំណត់ត្រាព័ត៌មានពាក់ព័ន្ធនឹងការនាំចូលនាំចេញថ្នាំកសិកម្ម
- ត្រូវជូនដំណឹងដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការត្រួតពិនិត្យដើមគ្រា នៅពេលនាំចូលនាំចេញ ឬនៅមុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ
- ត្រូវភ្ជាប់ឯកសារបញ្ជាក់ក្រុមហ៊ុន ឬសាខាដែលចុះកិច្ចសន្យាទទួលយកការផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មរបស់ខ្លួន
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣០.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូលថ្នាំកសិកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយសម្រាប់ការប្រើប្រាស់ផ្ទាល់ក្នុងកសិដ្ឋានគ្រប់ប្រភេទទោះឯកជន ឬរដ្ឋ និងសម្រាប់តម្រូវការសាធារណៈជាក់

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

លាក់ ឬសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវស្នើសុំលិខិតអនុញ្ញាតនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបញ្ជាក់អំពីប្រភេទថ្នាំកសិកម្ម គោលបំណងប្រើប្រាស់ និងបរិមាណសមស្របដែលត្រូវស្នើសុំនាំចូល ។

សំណើសុំនាំចូលសារធាតុគីមី ឬថ្នាំកសិកម្មប្រភេទគ្រោះថ្នាក់ខ្ពស់សម្រាប់គោលបំណងប្រើប្រាស់ចុងក្រោយជាក់លាក់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវអនុលោមតាមនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន ។

## អនុផ្នែកទី ២
## ថ្នាំកសិកម្មដែលធ្វើការលាយផ្សំ ការវេចខ្ចប់ជាថ្មី និងការធ្វើសន្និធិ

**មាត្រា ៣១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើពាណិជ្ជកម្មថ្នាំកសិកម្មគ្រប់ប្រភេទមានប្រភពចេញពីប្រតិបត្តិការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងរាល់ប្រតិបត្តិការនៃការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្ម ប្រតិបត្តិករត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម :

- ថ្នាំកសិកម្មត្រូវបានយល់ព្រមលើការចុះបញ្ជីរួចហើយ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ត្រូវជានាសារធាតុសកម្មដែលមានភាពពុលទាប ដោយអនុលោមតាមយថាប្រភេទបច្ចេកទេស ឬបមាណីយអន្តរជាតិដែលពាក់ព័ន្ធ
- ថ្នាំកសិកម្មត្រូវមានប្រភពចេញពីប្រតិបត្តិការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីដែលធានាសុវត្ថិភាពចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន
- ថ្នាំកសិកម្មដែលធ្វើការវេចខ្ចប់ជាថ្មីត្រូវមានប្រភពផ្គត់ផ្គង់ដែលបានអនុញ្ញាតស្របតាមច្បាប់នេះ និងត្រូវរក្សាបមាណីយដើមចេញពីប្រភពលាយផ្សំ
- ត្រូវអនុវត្តបមាណីយសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ
- ត្រូវមានកំណត់ត្រាព័ត៌មានក្នុងប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្ម
- ត្រូវជូនដំណឹងដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការត្រួតពិនិត្យដើមគ្រានៅមុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ
- ត្រូវភ្ជាប់ឯកសារបញ្ជាក់អំពីក្រុមហ៊ុន ឬសាខាដែលចុះកិច្ចសន្យាទទួលយកការផ្គត់ផ្គង់ ឬចែកចាយថ្នាំកសិកម្មរបស់ខ្លួន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

គោលការណ៍ណែនាំស្ដីពីការតម្រូវបមាណីយ និងវិធានសុវត្ថិភាពសម្រាប់ប្រតិបត្តិការលាយផ្សំ ការវេចខ្ចប់ និងការវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៣២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសន្និធិថ្នាំកសិកម្មក្នុងគោលបំណងធ្វើការផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្មនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងរាល់ការធ្វើសន្និធិថ្នាំកសិកម្ម អ្នកធ្វើសន្និធិត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម :

- ត្រូវស្ថាបនាឃ្លាំងសន្និធិលើទីតាំងដែលធានាសុវត្ថិភាពចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន
- ត្រូវអនុវត្តប្រព័ន្ធសុវត្ថិភាពសន្និធិថ្នាំកសិកម្មមានជាអាទិ៍ វិធានថែរក្សាឃ្លាំង វិធានរៀបចំគំនរ វិធានការពារនឹងការលេចជ្រាប ឬវិធានបំបាត់ភាពពុល និងវិធានសុវត្ថិភាពក្នុងពេលមានអាសន្ន
- ត្រូវគ្រប់គ្រងឲ្យមានសុវត្ថិភាពនូវថ្នាំកសិកម្មចាស់ដែលនៅសល់ក្នុងសន្និធិ
- ត្រូវធ្វើកំណត់ត្រាព័ត៌មានពាក់ព័ន្ធនឹងការធ្វើសន្និធិថ្នាំកសិកម្ម និងត្រូវរាយការណ៍ជូនអង្គភាពកសិកម្មមានសមត្ថកិច្ចអំពីថ្នាំកសិកម្មចាស់ដែលរក្សាក្នុងសន្និធិ
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

គោលការណ៍ណែនាំសម្រាប់ការធ្វើសន្និធិថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

## អនុផ្នែកទី ៣
## ការផ្គត់ផ្គង់ចែកចាយ និងការលក់ដុំលក់រាយ

**មាត្រា ៣៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មឲ្យសាខារបស់ខ្លួន ឬឲ្យគ្រឹះស្ថានលក់ដុំលក់រាយដែលស្ថិតនៅតាមរាជធានី ខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការលក់ដុំលក់រាយថ្នាំកសិកម្មក្នុងដែនរាជធានី ខេត្តនីមួយៗ ត្រូវមានលិខិតអនុញ្ញាតលក់ដុំលក់រាយចេញដោយមន្ទីរកសិកម្មរាជធានី ខេត្តសាមី ។

**មាត្រា ៣៤.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការផ្គត់ផ្គង់ចែកចាយ ឬធ្វើការលក់ដុំលក់រាយថ្នាំកសិកម្ម ត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម :

- ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងកាត់វគ្គអប់រំសមត្ថភាពវិជ្ជាជីវៈស្តីពី "កិច្ចប្រតិបត្តិតាំងលក់ល្អ" ដែលអនុលោមតាមកម្មវិធីសិក្សាកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អ្នកលក់ដុំលក់រាយត្រូវមានបញ្ជីឈ្មោះថ្នាំកសិកម្មដែលស្នើសុំលក់ និងសក្ខីបត្របញ្ជាក់ក្រុមហ៊ុនថ្នាំកសិកម្មដែលផ្គត់ផ្គង់ចែកចាយដល់គ្រឹះស្ថានលក់ដុំលក់រាយរបស់ខ្លួន
- អ្នកផ្គត់ផ្គង់ចែកចាយត្រូវមានកិច្ចសន្យាធ្វើជាអ្នកផ្គត់ផ្គង់ចែកចាយ ឬជាសាខារបស់ក្រុមហ៊ុនថ្នាំកសិកម្មដែលនាំចូល លាយផ្សំ ឬវេចខ្ចប់ជាថ្មី ហើយដែលកាន់កាប់លិខិតអនុញ្ញាតស្របតាមច្បាប់នេះ
- ត្រូវអនុវត្តបមាណីយសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ
- ត្រូវផ្គត់ផ្គង់ចែកចាយ ឬលក់ដុំលក់រាយថ្នាំកសិកម្មដែលមានការយល់ព្រមលើការចុះបញ្ជី និងត្រូវមានប្រភពដើមផ្គត់ផ្គង់ចែកចាយស្របតាមច្បាប់នេះ
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## អនុផ្នែកទី ៤
## សេវាកម្មកម្ចាត់សមាសភាពចង្រៃ

**មាត្រា ៣៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសេវាកម្មកម្ចាត់សមាសភាពចង្រៃនៅគ្រប់មជ្ឈដ្ឋានដោយប្រើថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងរាល់ប្រតិបត្តិការសេវាកម្មកម្ចាត់សមាសភាពចង្រៃ ប្រតិបត្តិករត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម :

- ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងកាត់វគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ដែលអនុលោមតាមកម្មវិធីសិក្សាកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- ត្រូវបញ្ជាក់ក្នុងកិច្ចសន្យាប្រតិបត្តិការនូវប្រភេទថ្នាំកសិកម្មដែលត្រូវប្រើ និងដែលត្រូវបានយល់ព្រមលើការចុះបញ្ជី ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ

- ត្រូវបំពាក់ឧបករណ៍ប្រើប្រាស់ក្នុងប្រតិបត្តិការដែលធានាសុវត្ថិភាពដល់បុគ្គលិកប្រតិបត្តិការ និងត្រូវមានកម្មវិធីថែទាំឧបករណ៍ការពារសុវត្ថិភាព

- ត្រូវមានកម្មវិធីការពារសុខភាពបុគ្គលិកប្រតិបត្តិការ ដែលប្រឈមជាមួយនឹងថ្នាំកសិកម្ម

- ត្រូវមានកំណត់ត្រាលើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្ម

- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣៦.-**

រាល់សាខារបស់ក្រុមហ៊ុនសេវាកម្មកម្ចាត់សមាសភាពចង្រៃដែលធ្វើសេវាកម្មនៅតាមរាជធានី ខេត្ត ត្រូវមានកិច្ចសន្យាសេវាកម្មប្រតិបត្តិការកម្ចាត់សមាសភាពចង្រៃ និងត្រូវមានបុគ្គលិកប្រតិបត្តិ-ការដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីទទួលខុសត្រូវជាអចិន្ត្រៃយ៍លើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្ម ។

## អនុផ្នែកទី ៥
## ការដឹកជញ្ជូនថ្នាំកសិកម្ម

**មាត្រា ៣៧.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដឹកជញ្ជូនថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តលក្ខខណ្ឌចាំបាច់ដូចខាងក្រោម :

១- ត្រូវប្រើមធ្យោបាយដឹកជញ្ជូន ឬមធ្យោបាយផ្ទុកដាច់ដោយឡែក ។

២- សម្រាប់គោលបំណងនាំចូលនាំចេញ ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតនាំចូលនាំចេញ ដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣- សម្រាប់គោលបំណងផ្គត់ផ្គង់ចែកចាយ ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងឯកសារពាក់ព័ន្ធដែលកំណត់ច្បាស់លាស់នូវប្រភេទ បរិមាណនៃថ្នាំកសិកម្ម និងទីតាំង ឬគ្រឹះស្ថានដែលទទួលយកការផ្គត់ផ្គង់ចែកចាយ ។

៤- ត្រូវដាក់តាំងលើមធ្យោបាយដឹកជញ្ជូន និងមធ្យោបាយផ្ទុកថ្នាំកសិកម្ម បង្ហាញនូវរូបសញ្ញា និងពាក្យសញ្ញាដើម្បីសម្គាល់ ស្របតាមចំណាត់ថ្នាក់គ្រោះថ្នាក់នៃប្រភេទថ្នាំកសិកម្មដែលដឹកជញ្ជូន

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រះបរមរាជវាំង

៥- ត្រូវបង្ហាញលិខិតអនុញ្ញាត ឬឯកសារពាក់ព័ន្ធដែលតម្រូវដោយច្បាប់នេះ ដើម្បីមន្ត្រីអធិការកិច្ចមានសមត្ថកិច្ច ធ្វើការត្រួតពិនិត្យ ។

**មាត្រា ៣៨.-**

ក្រុមហ៊ុនថ្នាំកសិកម្មដែលធ្វើការផ្គត់ផ្គង់ចែកចាយ ត្រូវផ្តល់ដល់អ្នកបើកបរមធ្យោបាយដឹកជញ្ជូនថ្នាំកសិកម្មរបស់ខ្លួននូវ "បណ្ណគ្រាអាសន្នដឹកជញ្ជូន" ដោយត្រូវបញ្ជាក់ព័ត៌មានចាំបាច់ដូចខាងក្រោម :

- ឈ្មោះ អាសយដ្ឋាន លេខទូរសព្ទទំនាក់ទំនងរបស់ក្រុមហ៊ុនសាមី
- ប្រភេទថ្នាំកសិកម្មដែលត្រូវដឹកជញ្ជូន
- គ្រោះថ្នាក់ជាមូលដ្ឋានដែលអាចប្រឈមដោយសារថ្នាំកសិកម្ម
- បទប្រុងប្រយ័ត្ន និងវិធានការដែលត្រូវអនុវត្ត ក្នុងករណីមានគ្រោះថ្នាក់ ឬមានអាសន្ន ។

ក្នុងករណីមានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរ លេចធ្លាយ ឬឆេះ អ្នកបើកបរមធ្យោបាយដឹកជញ្ជូនថ្នាំកសិកម្ម ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រុមហ៊ុនសាមី និងស្នើសុំអន្តរាគមន៍ពីនគរបាលចរាចរ ឬសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត និងត្រូវអនុវត្តវិធានការការពារនឹងគ្រោះថ្នាក់ដូចបានកំណត់ក្នុង "បណ្ណគ្រាអាសន្នដឹកជញ្ជូន" ។

**មាត្រា ៣៩.-**

ការដឹកជញ្ជូនថ្នាំកសិកម្មឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តលក្ខខណ្ឌចាំបាច់ដូចខាងក្រោម :

- ត្រូវធានាសុវត្ថិភាពក្នុងការដឹកជញ្ជូន ជៀសវាងការធ្លុះធ្លាយសម្ភារៈវេចខ្ចប់ ឬមធ្យោបាយផ្ទុកថ្នាំកសិកម្ម ឬជៀសវាងការសាយភាយដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន
- ត្រូវអនុវត្តនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនជូនស្ថាប័នមានសមត្ថកិច្ច ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញឆ្លងកាត់ សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ។

**មាត្រា ៤០.-**

នីតិវិធីនៃការគ្រប់គ្រងថ្នាំកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ៤
## សុវត្ថិភាពក្នុងការប្រើប្រាស់
## ក្នុងការបោះចោលសំណល់ពីការប្រើប្រាស់
## និងក្នុងការបំផ្លាញចោលថ្នាំកសិកម្ម

**មាត្រា ៤១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្ម ត្រូវមានការយល់ដឹងដូចខាងក្រោមៈ

- ត្រូវជ្រើសរើសប្រភេទថ្នាំកសិកម្មសមស្របសម្រាប់ប្រភេទដំណាំ ឬប្រភេទផលិតផល និងប្រភេទសមាសភាពចង្រៃ
- ត្រូវប្រើប្រាស់តែប្រភេទថ្នាំកសិកម្មដែលមិនស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់នៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានប្រភពដើមផ្គត់ផ្គង់ចែកចាយស្របតាមច្បាប់នេះ មានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ និងមានលេខបញ្ជិកាផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅលើសំបកវេចខ្ចប់
- ត្រូវប្រើប្រាស់ថ្នាំកសិកម្មស្របតាមសេចក្តីណែនាំអំពីការប្រើប្រាស់ និងត្រូវអនុវត្តតាមរយៈពេលបញ្ឈប់ការប្រើប្រាស់មុនពេលប្រមូលផលនៅលើស្លាកសញ្ញាព័ត៌មាននៃសំបកវេចខ្ចប់ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយល់ព្រមលើការចុះបញ្ជី
- ត្រូវយល់ដឹងពីបច្ចេកទេសប្រើប្រាស់ថ្នាំកសិកម្ម និងត្រូវប្រើប្រាស់ឧបករណ៍សុវត្ថិភាពក្នុងពេលធ្វើប្រព្រឹត្តិកម្មលើសមាសភាពចង្រៃ
- ត្រូវយល់ដឹងពីវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ដើម្បីទប់ស្កាត់ភាពប្រឈមនឹងគ្រោះថ្នាក់ចំពោះខ្លួនឯង អ្នកដទៃ និងបរិស្ថាន។

**មាត្រា ៤២.-**

ក្រុមហ៊ុនថ្នាំកសិកម្ម ឬម្ចាស់កសិដ្ឋាន ត្រូវមានករណីយកិច្ចចំពោះកម្មករនិយោជិតរបស់ខ្លួនដូចខាងក្រោម :

- ផ្តល់ការបណ្តុះបណ្តាលវិធានសុវត្ថិភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់ថ្នាំកសិកម្ម
- ផ្តល់ឧបករណ៍សុវត្ថិភាពដល់បុគ្គលិកប្រតិបត្តិការថ្នាំកសិកម្មផ្ទាល់
- កំណត់បទដ្ឋានសម្រាប់ឧបករណ៍ប្រើប្រាស់ថ្នាំកសិកម្មនិងឧបករណ៍ការពារសុវត្ថិភាព
- អនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាពជាប្រចាំ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្មគ្រប់ប្រភេទក្នុងកសិដ្ឋាន មានករណីយកិច្ចចូលរួមក្នុងគ្រប់សកម្មភាពអប់រំណែនាំស្តីពីវិធានសុវត្ថិភាពដោយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៣.-**

ការបោះចោលសំណល់ប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវអនុវត្តតាមវិធានដូចខាងក្រោម :

- មិនត្រូវបោះចោល កប់ ឬដុតបំផ្លាញសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម នៅទីកន្លែងដែលគ្មានការអនុញ្ញាតពីអង្គភាពកសិកម្ម ឬអាជ្ញាធរមានសមត្ថកិច្ច
- មិនត្រូវប្រើប្រាស់ឡើងវិញនូវសំបកវេចខ្ចប់ថ្នាំកសិកម្ម ដើម្បីវេចខ្ចប់ផលិតផលដែលមិនមែនជាថ្នាំកសិកម្ម ជាពិសេសចំណីអាហារ ឬចំណីសត្វ ។

គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះចោលសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

**មាត្រា ៤៤.-**

ប្រជាពលរដ្ឋគ្រប់រូបដែលបានឃើញ ឬបានដឹង មានករណីយកិច្ចផ្តល់ព័ត៌មានដល់អង្គភាពកសិកម្មមូលដ្ឋាន ឬអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត អំពីករណីផ្គត់ផ្គង់ចែកចាយ ប្រើប្រាស់ ឬបោះចោលសំណល់ថ្នាំកសិកម្មទាំងឡាយណាដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ។

**មាត្រា ៤៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្ម ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ ខូចខាតបរិស្ថាន ឬទ្រព្យសម្បត្តិសាធារណៈ ត្រូវជួសជុលការខូចខាត ឬត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន ។

**មាត្រា ៤៦.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីបញ្ឈប់ចរាចរណ៍ប្រភេទថ្នាំកសិកម្មណាមួយនៅលើទីផ្សារតាមការចាំបាច់ នៅពេលដែលទិន្នន័យស្រាវជ្រាវបង្ហាញថាបានបង្កគ្រោះថ្នាក់ចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន ដោយតម្រូវឲ្យក្រុមហ៊ុនទទួលខុសត្រូវក្នុងការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការនាំចូល និងការផ្គត់ផ្គង់ចែកចាយ ប្រមូលមកវិញនូវប្រភេទថ្នាំកសិកម្មនោះ ។

**មាត្រា ៤៧.-**

ថ្នាំកសិកម្មក្លែងបមាណីយ ថ្នាំកសិកម្មលាយផ្សំដោយគ្មានមូលដ្ឋានបច្ចេកទេស ថ្នាំកសិកម្មហាមឃាត់ ថ្នាំកសិកម្មមានប្រភពដើមល្មើសនឹងច្បាប់នេះ ត្រូវឃាត់ទុកជាបណ្តោះអាសន្ន ឬត្រូវរឹបអូសដើម្បីបំផ្លាញចោល ដោយអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

វិធានសម្រាប់ការបំផ្លាញចោលថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

## ផ្នែកទី ៥
## ការហាមឃាត់ពាក់ព័ន្ធនឹងថ្នាំកសិកម្ម

**មាត្រា ៤៨.-**

ត្រូវហាមឃាត់ចំពោះសកម្មភាពក្លែងនៅក្នុងពាណិជ្ជកម្មថ្នាំកសិកម្មគ្រប់ប្រភេទដូចខាងក្រោម :

១- ក្លែងលេខបញ្ជិកា។

២- ក្លែងបន្លំស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ឬប្រើស្លាកសញ្ញាព័ត៌មានជាភាសាបរទេស ។

៣- ក្លែងបន្លំសំបកវេចខ្ចប់ ។

៤- ក្លែងបន្លំឈ្មោះទូទៅ ឬឈ្មោះពាណិជ្ជកម្មនៃថ្នាំកសិកម្ម ។

៥- ក្លែងបន្លំសមាសធាតុ ឬមានសមាសធាតុផ្សេងពីការអះអាងនៅពេលស្នើសុំការចុះបញ្ជី ឬជាផលិតផលក្រៅបមាណីយ។

៦-ក្លែងបន្លំប្រភពដើម។

**មាត្រា ៤៩.-**

ត្រូវហាមឃាត់ចំពោះការប្រើប្រាស់ថ្នាំកសិកម្មគ្រប់ប្រភេទដូចខាងក្រោម :

១- ការប្រើប្រាស់ថ្នាំកសិកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់នៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីកម្ចាត់សមាសភាពចង្រៃគ្រប់ប្រភេទ។

២- ការប្រើប្រាស់ថ្នាំកសិកម្មលើដំណាំស្បៀងគ្រប់ប្រភេទ ឬលើស្មៅចំណីសត្វ មុនពេលប្រមូលផល មិនស្របតាមរយៈពេលបញ្ឈប់ការប្រើប្រាស់មុនពេលប្រមូលផល ដែលកំណត់លើស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្ម និងត្រូវបានយល់ព្រមក្នុងការចុះបញ្ជី ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣- ការប្រើប្រាស់ថ្នាំកសិកម្ម ឬការធ្វើសេវាកម្មដោយប្រើថ្នាំកសិកម្មប្រភេទនិយ័តករការលូតលាស់ឬប្រភេទជំរុញការលូតលាស់របស់រុក្ខជាតិឬដំណាំខុសប្រក្រតីលើសពីកម្រិតប្រើប្រាស់ ឬលាយចម្រុះជាមួយនឹងសារធាតុគីមីគ្រោះថ្នាក់ដែលហាមឃាត់ ឬលាយជាមួយនឹងសារធាតុគីមីផ្សេងទៀតដោយផ្ទុយនឹងបទដ្ឋានបច្ចេកទេស ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ។

**មាត្រា ៥០.-**

ត្រូវហាមឃាត់ចំពោះគ្រប់សកម្មភាពពាណិជ្ជកម្មថ្នាំកសិកម្មដូចខាងក្រោម :

១- ពាណិជ្ជកម្មថ្នាំកសិកម្មស្ថិតក្នុងចំណាត់ថ្នាក់ពុលខ្ពស់ដែលហាមឃាត់ក្នុងបញ្ជីថ្នាំកសិកម្មនៃព្រះរាជាណាចក្រកម្ពុជាឬអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ។

២- ពាណិជ្ជកម្មថ្នាំកសិកម្មដែលជាផលិតផលក្រោមបមាណីយ ឬផុតសុពលភាពប្រើប្រាស់ដែលបានកំណត់លើស្លាកសញ្ញាព័ត៌មាន។

៣- ការបង្កើតឃ្លាំងសន្និធិថ្នាំកសិកម្មសម្រាប់គ្រប់ប្រតិបត្តិការពាណិជ្ជកម្មនៅជិតបរិវេណទីផ្សារ ទីសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម សាលារៀន មន្ទីរពេទ្យ ឬប្រភពទឹកដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព ផលប្រយោជន៍អ្នកជិតខាង សាធារណជន និងបរិស្ថាន ។

៤- ការដាក់តាំងលក់ ឬការធ្វើសន្និធិសម្រាប់លក់ថ្នាំកសិកម្មនៅក្នុងបរិវេណទីផ្សារ ទីសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម ឬនៅលើទីកន្លែងរួមជាមួយនឹងស្បៀងអាហារ ចំណីសត្វ ឬលាយចម្រុះជាមួយនឹងទំនិញផ្សេងទៀត ដែលងាយបង្កគ្រោះថ្នាក់ដល់សុខភាព ផលប្រយោជន៍អ្នកជិតខាង សាធារណជន និងបរិស្ថាន ។

៥- ការដឹកជញ្ជូនថ្នាំកសិកម្ម ដើម្បីចល័តលក់ឬផ្គត់ផ្គង់ចែកចាយដោយផ្ទាល់ដល់អ្នកប្រើប្រាស់ចុងក្រោយ ដោយគ្មានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយ ឬដោយមានប្រភពដើមល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

៦- ការដឹកជញ្ជូនឬការផ្ទុកថ្នាំកសិកម្មនៅរួមជាមួយនឹងអ្នកដំណើរ សត្វ ទំនិញ ឬជាមួយនឹងស្បៀងអាហារសម្រាប់មនុស្ស ឬចំណីសត្វដែលងាយបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ។

៧- ការផ្គត់ផ្គង់ចែកចាយ ឬការលក់ដុំលក់រាយថ្នាំកសិកម្មដែលបានអនុញ្ញាតឲ្យនាំចូលសម្រាប់តែការប្រើប្រាស់ចុងក្រោយ ឬការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មជាក់លាក់ណាមួយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៥១.-**

ត្រូវហាមឃាត់ចំពោះការនាំចូលសំណល់ថ្នាំកសិកម្ម ឬសំបកវេចខ្ចប់ថ្នាំកសិកម្មដែលប្រើរួច ឬថ្នាំកសិកម្មចាស់ ផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះនិងអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ។

ត្រូវហាមឃាត់ចំពោះការបោះចោល ការកប់ចោល ការដុតចោល ការចាក់ចូល ឬការបង្ហូរចូល ដោយចេតនានូវសំណល់ថ្នាំកសិកម្ម សំបកវេចខ្ចប់ថ្នាំកសិកម្ម ឬថ្នាំកសិកម្មចាស់ទៅក្នុងប្រភពទឹក ឬក្នុងមជ្ឈដ្ឋានផ្សេងទៀតផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី ៤
## ការគ្រប់គ្រងជីកសិកម្ម

### ផ្នែកទី ១
### ការចុះបញ្ជីជីកសិកម្ម និងការតម្រូវបមាណីយ

**មាត្រា ៥២.-**

ជីកសិកម្មគ្រប់ប្រភេទអាចធ្វើពាណិជ្ជកម្ម ឬធ្វើការលាយផ្សំនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានលុះត្រាតែប្រភេទជីកសិកម្មទាំងនោះ ត្រូវបានយល់ព្រមលើការចុះបញ្ជីតាមបទប្បញ្ញត្តិនៃច្បាប់ នេះ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូលនាំចេញជីកសិកម្ម ឬធ្វើការលាយផ្សំក្នុងគោលបំណងធ្វើពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវស្នើសុំការចុះបញ្ជីប្រភេទជីកសិកម្មនោះជាមុន នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់បញ្ជីជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយចាត់ថ្នាក់តាមក្រុមប្រភេទ និងយថាប្រភេទតាមបមាណីយយថាប្រភេទអន្តរជាតិដែលពាក់ព័ន្ធ ។

**មាត្រា ៥៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជីកសិកម្ម មានកាតព្វកិច្ចបំពេញការតម្រូវបមាណីយដោយត្រូវផ្តល់ព័ត៌មានពេញលេញ និងត្រឹមត្រូវសម្រាប់ការពិនិត្យនិងវាយតម្លៃ ។

**មាត្រា ៥៤.-**

ការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម ត្រូវធានាឲ្យមានព័ត៌មាន និងទិន្នន័យដូចខាងក្រោម

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- អត្តសញ្ញាណរបស់ក្រុមហ៊ុនស្នើសុំការចុះបញ្ជី អត្តសញ្ញាណប្រភេទជីកសិកម្ម និងដំណើរការលាយផ្សំ

- ទិន្នន័យថាប្រភេទនៃជីកសិកម្ម និងបមាណីយជានានៃសារជាតុចិញ្ចឹម វិញ្ញាបនបត្រប្រភពដើមបញ្ជាក់លទ្ធផលវិភាគសារជាតុចិញ្ចឹម និងវិធីសាស្ត្រវិភាគ

- ទិន្នន័យជីវប្រសិទ្ធភាពចេញពីប្រទេសប្រភពដើម និងរបាយការណ៍អំពីការសាកល្បងជីវប្រសិទ្ធភាពលើទីវាលពិសោធន៍

- សំបកវេចខ្ចប់ ស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ និងបរិយាយបណ្ណ

- ទិន្នន័យភាពពុលនៃជីកសិកម្ម

- ទិន្នន័យ ឬព័ត៌មានផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៥.-**

ជីកសិកម្មគ្រប់ប្រភេទដែលស្នើសុំការចុះបញ្ជីត្រូវឆ្លងកាត់ការវិភាគសំណាក ដើម្បីផ្ទៀងផ្ទាត់បមាណីយជានានៃសារជាតុចិញ្ចឹម ឬសមាសធាតុនៅមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលមានការទទួលស្គាល់ដូចមានចែងក្នុងមាត្រា ៨៧ នៃច្បាប់នេះ ។

គោលការណ៍ណែនាំសម្រាប់សំណាកជីកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៦.-**

លើកលែងតែប្រភេទជីអសរីរាង្គធម្មតាដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជីសរីរាង្គ ជីជីវសាស្ត្រ ឬជីកសិកម្មផ្សេងទៀតដែលមានទិន្នន័យមិនគ្រប់គ្រាន់សម្រាប់ការវាយតម្លៃលើសំណើសុំការចុះបញ្ជី តម្រូវឲ្យធ្វើការសាកល្បងជីវប្រសិទ្ធភាពដោយស្ថានីយពិសោធន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយអ្នកស្រាវជ្រាវដែលមានការទទួលស្គាល់ដូចមានចែងក្នុងមាត្រា ៨៧ នៃច្បាប់នេះ ។

ពិធីសារសាកល្បងជីវប្រសិទ្ធភាពនៃជីកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៧.-**

គំរូស្លាកសញ្ញាព័ត៌មាននៃជីកសិកម្មដែលប្រើប្រាស់លើសំបកវេចខ្ចប់គ្រប់ប្រភេទត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ការតម្រូវបមាណីយសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជីកសិកម្ម មានដូចខាងក្រោម :

- ត្រូវធានាការរចនា និងការផលិតពីវត្ថុធាតុដែលជាប់មាំល្អ ដើម្បីសម្រួលដល់ការដឹកជញ្ជូន ការធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់ ហើយដែលធន់នឹងធាតុអាកាស មិនប្រែប្រួលលក្ខណៈរូបនិងគីមីនៃជីកសិកម្ម
- គ្រប់ព័ត៌មាននៅលើស្លាកសញ្ញាព័ត៌មាន ត្រូវតែមានជាភាសាខ្មែរ អាចអានបានងាយយល់ និងមិនងាយរលុប
- ស្លាកសញ្ញាព័ត៌មានត្រូវបោះពុម្ពផ្ទាល់លើសំបកវេចខ្ចប់ និងត្រូវប្រើបរិយាយបណ្ណព័ត៌មានបន្ថែមតាមការចាំបាច់
- ការតម្រូវបមាណីយផ្សេងទៀតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៨.-**

សំបកវេចខ្ចប់ជីកសិកម្មគ្រប់ប្រភេទ ត្រូវធានាស្លាកសញ្ញាព័ត៌មានដែលបង្ហាញព័ត៌មានដូចខាងក្រោម :

- ឈ្មោះ និងអាសយដ្ឋានរបស់ក្រុមហ៊ុនកាន់កាប់បញ្ជិកាផលិតផល
- ឈ្មោះទូទៅ ឈ្មោះពាណិជ្ជកម្មនៃជីកសិកម្ម និងពាណិជ្ជសញ្ញា
- សារធាតុចិញ្ចឹម ឬសមាសធាតុនៃជីកសិកម្ម
- លេខបញ្ជិកាផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រុមហ៊ុន និងប្រទេសប្រភពដើមលាយផ្សំឬនាំចេញ
- របៀបប្រើប្រាស់ និងសេចក្តីណែនាំផ្សេងៗ
- កាលបរិច្ឆេទ និងសុពលភាពប្រើប្រាស់
- ទម្ងន់សុទ្ធសាធ
- ការធានា និងបម្រាម
- លេខ គំនរ ឬលេខឡូត៍
- ព័ត៌មានផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

គំរូស្លាកសញ្ញាព័ត៌មានសម្រាប់ជីកសិកម្ម ត្រូវបានកំណត់ក្នុងនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៩.-**

វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្មដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់តាមប្រភេទបញ្ជិកា រួមមានបញ្ជិកាពេញលេញ និងបញ្ជិកាបណ្តោះអាសន្ន ។

វិញ្ញាបនបត្របញ្ជាក់បញ្ជិកាពេញលេញជីកសិកម្ម ត្រូវមានសុពលភាពរយៈពេល ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកា លើកលែងតែមានការដកហូតនៅមុនពេលផុតសុពលភាព ។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់កាប់បញ្ជិកាពេញលេញជីកសិកម្ម អាចស្នើសុំការចុះបញ្ជីជាថ្មីដោយត្រូវបំពេញសំណុំបែបបទ និងសម្រង់ព័ត៌មានតាមនីតិវិធីនៃច្បាប់នេះ ។

បញ្ជិកាបណ្តោះអាសន្នជីកសិកម្មអាចផ្ទេរទៅជាបញ្ជិកាពេញលេញក្នុងរយៈពេលមួយឆ្នាំ នៅពេលដែលបណ្តាលក្ខខណ្ឌ និងការតម្រូវទាំងឡាយត្រូវបានបំពេញគ្រប់គ្រាន់ ។ ក្នុងករណីមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ បញ្ជិកាបណ្តោះអាសន្ននោះត្រូវទុកជានិរាករណ៍ ។ រូបវន្តបុគ្គល ឬនីតិ-បុគ្គលដែលកាន់កាប់បញ្ជិកាបណ្តោះអាសន្នមិនអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មប្រភេទជីកសិកម្មនោះបានឡើយ ។

**មាត្រា ៦០.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបដិសេធសំណើសុំការចុះបញ្ជីប្រភេទជីកសិកម្មផ្អែកតាមលក្ខណវិនិច្ឆ័យណាមួយដូចខាងក្រោម :

១- ព័ត៌មាន ទិន្នន័យ ដែលអះអាងក្នុងសំណុំបែបបទស្នើសុំការចុះបញ្ជីមានភាពមិនពិត ។

២- មិនទាន់មានទិន្នន័យស្រាវជ្រាវច្បាស់លាស់អំពីប្រភេទជីកសិកម្មនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៣- បមាណីយជានានៃសមាសធាតុជីកសិកម្ម មានកម្រិតទាបជាងបមាណីយ អនុគ្រោះសម្រាប់ការចុះបញ្ជី ។

៤- វត្ថុធាតុដើម ឬសមាសធាតុជីកសិកម្មត្រូវបានហាមឃាត់ក្នុងក្របខ័ណ្ឌសុវត្ថិភាពស្បៀង ឬមានសក្តានុពលភាពហានិភ័យចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន ។

**មាត្រា ៦១.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុគ្រោះការតម្រូវបមាណីយលើការចុះបញ្ជីជីកសិកម្មសម្រាប់តម្រូវការសាធារណៈ សម្រាប់ប្រើក្នុងវិស័យសិក្សាធិការ សុខភាពសាធារណៈ និងការស្រាវជ្រាវ ឬសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មផ្សេងទៀតតាមការចាំបាច់ ។

**មាត្រា ៦២.-**

រាល់ទិន្នន័យដែលបានភ្ជាប់ ឬអះអាងសម្រាប់បញ្ជិកាពេញលេញ ឬបញ្ជិកាបណ្ដោះអាសន្ន របស់ជីកសិកម្មតាមរយៈការសាកល្បងលើទីវាលពិសោធន៍ ត្រូវបានផ្ដល់ការការពារសិទ្ធិលើទិន្នន័យ ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកាតាមការស្នើសុំ ។

**មាត្រា ៦៣.-**

នីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី ២
## ការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម

**មាត្រា ៦៤.-**

បន្ថែមលើបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការគ្រប់គ្រងពាណិជ្ជកម្ម គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមានសិទ្ធិធ្វើពាណិជ្ជកម្មជីកសិកម្មគ្រប់ប្រភេទដែលមានប្រភពចេញពីប្រតិបត្តិការ រួមមានការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការលក់ដុំលក់រាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានលិខិតអនុញ្ញាតឡើយ ហើយរូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយ និងវិធានសុវត្ថិភាពដែលតម្រូវដោយបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៦៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូលនាំចេញជីកសិកម្ម ត្រូវមានលិខិតអនុញ្ញាតដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងរាល់ប្រតិបត្តិការនាំចូលនាំចេញជីកសិកម្មគ្រប់ប្រភេទ អ្នកនាំចូលនាំចេញត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម :

- ប្រភេទជីកសិកម្មត្រូវបានយល់ព្រមលើការចុះបញ្ជីរួចហើយ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ
- ត្រូវអនុវត្តបមាណីយសំបកវេចខ្ចប់ ស្លាកសញ្ញាព័ត៌មាន ឬបរិយាយបណ្ណសម្រាប់ការណែនាំជាភាសាខ្មែរ ដែលត្រូវបានយល់ព្រមចុះបញ្ជី
- ត្រូវមានកំណត់ត្រាព័ត៌មានពាក់ព័ន្ធនឹងការនាំចូលនាំចេញជីកសិកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ត្រូវជូនដំណឹងដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការត្រួតពិនិត្យដើមគ្រា នៅមុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ
- ត្រូវមានវិញ្ញាបនបត្របញ្ជាក់លទ្ធផលវិភាគបមាណីយជានានៅមុនពេលនាំចេញ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសប្រភពដើមនាំចេញ
- ត្រូវភ្ជាប់ឯកសារបញ្ជាក់ក្រុមហ៊ុន ឬសាខាដែលចុះកិច្ចសន្យាទទួលការផ្គត់ផ្គង់ចែកចាយជីកសិកម្មរបស់ខ្លួន
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦៦.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូលជីកសិកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយសម្រាប់ការប្រើប្រាស់ផ្ទាល់ក្នុងកសិដ្ឋានគ្រប់ប្រភេទ ទោះជាឯកជន ឬរដ្ឋ និងសម្រាប់តម្រូវការសាធារណៈជាក់លាក់ ឬសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មផ្សេងទៀត ត្រូវស្នើសុំលិខិតអនុញ្ញាតនាំចូលនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបញ្ជាក់អំពីប្រភេទជីកសិកម្ម គោលបំណងប្រើប្រាស់ និងបរិមាណសមស្របដែលត្រូវស្នើសុំនាំចូល ។

**មាត្រា ៦៧.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើពាណិជ្ជកម្មជីកសិកម្មគ្រប់ប្រភេទមានប្រភពចេញពីប្រតិបត្តិការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងរាល់ប្រតិបត្តិការនៃការលាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវជីកសិកម្មគ្រប់ប្រភេទ ប្រតិបត្តិករត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម :

- ជីកសិកម្មត្រូវបានយល់ព្រមលើការចុះបញ្ជីរួចហើយ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ជីកសិកម្មត្រូវមានប្រភពចេញពីប្រតិបត្តិការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីដែលមានទីតាំងសមស្រប និងធានាសុវត្ថិភាពចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន
- ជីកសិកម្មដែលធ្វើការវេចខ្ចប់ជាថ្មី ត្រូវមានប្រភពផ្គត់ផ្គង់ចែកចាយដែលបានអនុញ្ញាតស្របតាមច្បាប់នេះ និងត្រូវរក្សាបមាណីយដើមដែលបានអះអាងនៅក្នុងការចុះបញ្ជី
- ត្រូវអនុវត្តបមាណីយសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ត្រូវមានកំណត់ត្រាព័ត៌មានក្នុងប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវជីកសិកម្ម
- ត្រូវជូនដំណឹងដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការត្រួតពិនិត្យដើមគ្រា នៅមុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ
- ត្រូវភ្ជាប់ឯកសារបញ្ជាក់អំពីក្រុមហ៊ុន ឬសាខាដែលចុះកិច្ចសន្យាទទួលយកការផ្គត់ផ្គង់ចែកចាយជីកសិកម្មរបស់ខ្លួន
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦៨.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសន្និធិជីកសិកម្មក្នុងគោលបំណងធ្វើការផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងរាល់ការធ្វើសន្និធិជីកសិកម្ម អ្នកធ្វើសន្និធិត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម :

- ត្រូវស្ថាបនាឃ្លាំងសន្និធិលើទីតាំងសមស្រប និងធានាសុវត្ថិភាពចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន
- ត្រូវគ្រប់គ្រងនិងថែទាំឃ្លាំងសន្និធិឲ្យមានសុវត្ថិភាព ដើម្បីរក្សាបមាណីយដើមនៃផលិតផលក្នុងការធ្វើសន្និធិ
- ត្រូវមានកំណត់ត្រាព័ត៌មានពាក់ព័ន្ធនឹងការធ្វើសន្និធិជីកសិកម្ម
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦៩.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការផ្គត់ផ្គង់ចែកចាយជីកសិកម្មដល់សាខារបស់ខ្លួន ឬគ្រឹះស្ថានលក់ដុំលក់រាយដែលស្ថិតតាមរាជធានីខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការលក់ដុំលក់រាយជីកសិកម្មក្នុងដែនរាជធានី ខេត្តនីមួយៗ ត្រូវមានលិខិតអនុញ្ញាតលក់ដុំលក់រាយចេញដោយមន្ទីរកសិកម្មរាជធានី ខេត្តសាមី ។



**មាត្រា ៧០.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការផ្គត់ផ្គង់ចែកចាយ ឬធ្វើការលក់ដុំ លក់រាយជីកសិកម្ម ត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម :

- ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងកាត់វគ្គអប់រំសមត្ថភាពវិជ្ជាជីវៈស្តីពី "កិច្ចប្រតិបត្តិតាំងលក់ល្អ" ដែលអនុលោមតាមកម្មវិធីសិក្សាកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អ្នកផ្គត់ផ្គង់ចែកចាយត្រូវមានកិច្ចសន្យាធ្វើជាអ្នកផ្គត់ផ្គង់ចែកចាយ ឬជាសាខារបស់ក្រុមហ៊ុនដែលនាំចូល លាយផ្សំ ឬវេចខ្ចប់ជាថ្មី ហើយដែលកាន់កាប់លិខិតអនុញ្ញាតស្របតាមច្បាប់នេះ
- អ្នកលក់ដុំលក់រាយត្រូវមានបញ្ជីប្រភេទជីកសិកម្មដែលស្នើសុំលក់ និងសក្ខីបត្របញ្ជាក់ក្រុមហ៊ុនជីកសិកម្មដែលផ្គត់ផ្គង់ចែកចាយដល់គ្រឹះស្ថានលក់ដុំលក់រាយរបស់ខ្លួន
- ត្រូវអនុវត្តបមាណីយសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ
- ត្រូវផ្គត់ផ្គង់ចែកចាយ ឬលក់ដុំលក់រាយជីកសិកម្មគ្រប់ប្រភេទដែលមានការយល់ព្រមលើការចុះបញ្ជី និងត្រូវមានប្រភពដើមផ្គត់ផ្គង់ចែកចាយស្របតាមច្បាប់នេះ
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៧១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដឹកជញ្ជូនជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តលក្ខខណ្ឌចាំបាច់ដូចខាងក្រោម :

១- សម្រាប់គោលបំណងនាំចូលនាំចេញ ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតនាំចូលនាំចេញដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

២- សម្រាប់គោលបំណងផ្គត់ផ្គង់ចែកចាយ ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងឯកសារពាក់ព័ន្ធដែលកំណត់នូវប្រភេទ បរិមាណនៃជីកសិកម្ម និងទីតាំង ឬគ្រឹះស្ថានដែលទទួលយកការផ្គត់ផ្គង់ចែកចាយ ។

៣- ត្រូវបង្ហាញលិខិតអនុញ្ញាត ឬឯកសារពាក់ព័ន្ធដែលតម្រូវដោយច្បាប់នេះ ដើម្បីមន្ត្រីអធិការកិច្ចមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការត្រួតពិនិត្យ ។

**មាត្រា ៧២.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវគ្រប់គ្រងចរាចរណ៍ និងការបោះចោលជីកសិកម្មខូចគុណភាព ឬជីកសិកម្មក្រៅបមាណីយ ដោយផ្តល់គោលការណ៍ណែនាំដល់ពាណិជ្ជករជីកសិកម្មក្នុងការទទួលខុសត្រូវចំពោះសកម្មភាពដែលពាក់ព័ន្ធ ។

ជីកសិកម្មខូចគុណភាព ឬជីកសិកម្មក្រៅបមាណីយ ត្រូវធ្វើសន្និធិដាច់ដោយឡែក និងត្រូវដាក់សញ្ញាសម្គាល់លើសំបកវេចខ្ចប់ ដើម្បីការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់ចុងក្រោយ ។

ត្រូវហាមឃាត់ការធ្វើពាណិជ្ជកម្មជីកសិកម្មខូចគុណភាព ឬជីកសិកម្មក្រៅបមាណីយ ឬធ្វើការបោះចោលដោយបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ។

**មាត្រា ៧៣.-**

ត្រូវហាមឃាត់ចំពោះសកម្មភាពក្លែងនៅក្នុងពាណិជ្ជកម្មជីកសិកម្មដូចខាងក្រោម :

១- ក្លែងលេខបញ្ជិកា ។

២- ក្លែងបន្លំស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ឬប្រើស្លាកសញ្ញាព័ត៌មានជាភាសាបរទេស ។

៣- ក្លែងបន្លំសំបកវេចខ្ចប់ ឬកាន់កាប់ឧបករណ៍សម្រាប់វេចខ្ចប់ក្លែងជីកសិកម្ម ។

៤- ក្លែងបន្លំសមាសធាតុ ឬមានសមាសធាតុផ្សេងពីការអះអាងនៅពេលស្នើសុំការចុះបញ្ជី ឬជាផលិតផលក្រៅបមាណីយ ។

៥- ក្លែងបន្លំប្រភពដើម ។

**មាត្រា ៧៤.-**

ត្រូវហាមឃាត់ចំពោះសកម្មភាពពាក់ព័ន្ធនឹងជីកសិកម្មដូចខាងក្រោម :

១- ធ្វើការលាយផ្សំជីកសិកម្មដោយប្រើប្រាស់សារធាតុជំរុញការលូតលាស់របស់រុក្ខជាតិ ឬដំណាំលើសកម្រិតខុសប្រក្រតី សារធាតុដែលគ្រោះថ្នាក់ ឬសារធាតុហាមឃាត់ ។

២- ធ្វើពាណិជ្ជកម្មជីកសិកម្មដែលជាផលិតផលក្រោមបមាណីយ ឬជីកសិកម្មផុតសុពលភាពប្រើប្រាស់ដូចបានកំណត់លើស្លាកសញ្ញាព័ត៌មាន ។

៣- ការដឹកជញ្ជូនជីកសិកម្មដើម្បីចល័តលក់ឬផ្គត់ផ្គង់ចែកចាយដោយផ្ទាល់ដល់អ្នកប្រើប្រាស់ចុងក្រោយដោយគ្មានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយដែលតម្រូវដោយច្បាប់នេះ ។

៤- ការផ្គត់ផ្គង់ចែកចាយ ឬការលក់ដុំលក់រាយជីកសិកម្មដែលអនុញ្ញាតឲ្យនាំចូលសម្រាប់តែការប្រើប្រាស់ចុងក្រោយ ឬការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មជាក់លាក់ណាមួយ ។

៥- ការកែច្នៃ និងការប្រើប្រាស់ប្រភេទជីអ៊ុយរ៉េ ឬជីកសិកម្មផ្សេងទៀតក្នុងគោលបំណងផលិតគ្រឿងផ្ទុះ ឬប្រើប្រាស់ដែលបង្កឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ។

**មាត្រា ៧៥.-**

នីតិវិធីនៃការប្រើប្រាស់ប្រភេទជីអ៊ុយរ៉េ ឬជីកសិកម្មផ្សេងទៀតដែលអាចកែច្នៃ ឬផលិតជាគ្រឿងផ្ទុះ ឬបង្កឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៥
## ការផ្សាយពាណិជ្ជកម្ម

**មាត្រា ៧៦.-**

បន្ថែមលើបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការផ្សាយព័ត៌មាន គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមានសិទ្ធិធ្វើការផ្សាយពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្មដោយគ្មានការយល់ព្រមជាមុនលើការចុះបញ្ជីនៃផលិតផលទាំងនេះដែលតម្រូវដោយច្បាប់នេះឡើយ ។

រាល់អត្ថបទ ការបោះពុម្ព ឬរូបភាពសោតទស្សន៍ផ្សាយពាណិជ្ជកម្មអំពីថ្នាំកសិកម្ម ឬជីកសិកម្មគ្រប់ប្រភេទ ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៧៧.-**

ការផ្សាយពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្មត្រូវអនុវត្តវិធានដូចខាងក្រោម :

- អត្ថបទផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយពាណិជ្ជកម្ម តាមរយៈការបង្ហាញដោយប្រើថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវមានខ្លឹមសារបច្ចេកទេសសមស្រប និងមានសង្គតិភាពនឹងទិន្នន័យព័ត៌មានបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការផ្សាយពាណិជ្ជកម្មត្រូវណែនាំឲ្យអ្នកទិញ ឬអ្នកប្រើប្រាស់អានស្លាកសញ្ញាព័ត៌មានលើសំបកវេចខ្ចប់ឲ្យបានយល់ច្បាស់ និងត្រូវមានការប្រុងប្រយ័ត្នចំពោះអត្ថបទណែនាំ រូបសញ្ញាគ្រោះថ្នាក់ និងរូបសញ្ញាហាមឃាត់
- អត្ថបទផ្សាយពាណិជ្ជកម្មត្រូវផ្តល់ព័ត៌មានច្បាស់លាស់អំពីការអនុវត្តត្រឹមត្រូវតាមវិធីប្រើប្រាស់ និងរយៈពេលបញ្ឈប់ការប្រើប្រាស់មុនប្រមូលផល
- បុគ្គលិកដែលបម្រើការងារផ្សាយពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្ម ត្រូវមានសមត្ថភាពវិជ្ជាជីវៈដើម្បីផ្តល់ព័ត៌មានឲ្យបានត្រឹមត្រូវច្បាស់លាស់អំពីថ្នាំកសិកម្ម ឬជីកសិកម្ម ។

**មាត្រា ៧៨.-**

ការផ្សាយពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្មត្រូវជៀសវាង :

- ផ្តល់រង្វាន់លើកទឹកចិត្តដើម្បីជំរុញការប្រើប្រាស់
- ធ្វើការប្រៀបធៀបប្រសិទ្ធភាព ឬសុវត្ថិភាពជាមួយប្រភេទថ្នាំកសិកម្ម ឬជីកសិកម្មដទៃទៀតគ្រប់ប្រភេទ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- ប្រើប្រាស់បញ្ញិកា ឬការយល់ព្រមដោយអាជ្ញាធរនៃប្រទេសណាមួយដើម្បីឃោសនាប្រសិទ្ធភាពនិងសុវត្ថិភាពផលិតផល ។

**មាត្រា ៧៩.-**

ត្រូវហាមឃាត់ការផ្សាយពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្មដូចខាងក្រោម :

១- ជំរុញការប្រើប្រាស់លើសកម្រិតបមាណីយដែលកំណត់ដោយបទដ្ឋានបច្ចេកទេស ។

២- បំភាន់អ្នកទិញដោយភូតកុហក បំផ្លើសអំពីប្រសិទ្ធភាព និងសុវត្ថិភាពនៃផលិតផលតាមអត្ថបទឃោសនា ឬការឃោសនាតាមប្រព័ន្ធផ្សព្វផ្សាយ ឬការឃោសនាផ្ទាល់មាត់ ឬដោយប្រើខ្លឹមសារដូចជា : "មិនពុល" "គ្មានគ្រោះថ្នាក់" "មិនប៉ះពាល់បរិស្ថាន និងសុខភាព" ។ល។

## ជំពូកទី ៦
## ការស្រាវជ្រាវ
## ថ្នាំកសិកម្ម និងជីកសិកម្ម

**មាត្រា ៨០.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តកម្មវិធីសិក្សា ពិសោធ ស្រាវជ្រាវ ថ្នាំកសិកម្ម និងជីកសិកម្ម ដូចខាងក្រោម :

- តាមដាន ប្រមូលព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងថ្នាំកសិកម្ម និងជីកសិកម្មដែលធ្វើពាណិជ្ជកម្ម និងប្រើប្រាស់ ដោយចងក្រងកំណត់ត្រា និងរបាយការណ៍ស្តីពីប្រសិទ្ធិភាព ផលប៉ះពាល់ និងគ្រោះថ្នាក់ចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន ដើម្បីកំណត់វិធានការកែលម្អក្នុងការគ្រប់គ្រង

- ស្រាវជ្រាវលើប្រភេទថ្នាំកសិកម្ម និងជីកសិកម្មនីមួយៗ ស្របតាមស្ថានភាពជាក់ស្តែងនៃក្សេត្របរិស្ថានក្នុងប្រទេស ដើម្បីកំណត់បមាណីយក្នុងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពនៅក្នុងផលិតកម្មកសិកម្ម

- សិក្សា វាយតម្លៃលើផ្នែកបច្ចេកទេសសម្រាប់ការចុះបញ្ជីផលិតផលថ្មីនៃថ្នាំកសិកម្ម និងជីកសិកម្ម

- ធ្វើសហប្រតិបត្តិការ និងសម្របសម្រួលជាមួយនឹងអង្គភាព ឬស្ថាប័នស្រាវជ្រាវពាក់ព័ន្ធក្នុងការប្រមូលព័ត៌មានអំពីថ្នាំកសិកម្ម និងជីកសិកម្ម

- អនុវត្តកម្មវិធីស្រាវជ្រាវផ្សេងទៀតពាក់ព័ន្ធនឹងថ្នាំកសិកម្ម និងជីកសិកម្ម ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ៨១.-**

កម្មវិធីស្រាវជ្រាវថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវទ្រទ្រង់តាមរយៈ :

- ថវិកាជាតិប្រចាំឆ្នាំ
- គម្រោងជំនួយពីប្រភពនានា
- ប្រភពហិរញ្ញវត្ថុផ្សេងទៀត ។

## ជំពូកទី ៧
## វិធានរួមសម្រាប់ពាណិជ្ជករ
## ថ្នាំកសិកម្ម និងជីកសិកម្ម

### ផ្នែកទី ១
### ភារកិច្ចពាណិជ្ជករ

**មាត្រា ៨២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នេះលើរាល់ថ្នាំកសិកម្ម ឬជីកសិកម្ម ដែលដាក់តាំងលក់ ឬធ្វើសន្និធិសម្រាប់លក់នៅក្នុងគ្រឹះស្ថានពាណិជ្ជកម្ម ឬឃ្លាំងសន្និធិរបស់ខ្លួន ដោយត្រូវធ្វើសហការ និងបង្កលក្ខណៈងាយស្រួលដល់គ្រប់សកម្មភាពអប់រំណែនាំ ត្រួតពិនិត្យ និងអនុវត្តច្បាប់របស់មន្ត្រីអធិការកិច្ចមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ពាណិជ្ជករថ្នាំកសិកម្ម និងជីកសិកម្ម មានភារកិច្ចដូចខាងក្រោម :

- ត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិ និងត្រូវតម្កល់ឯកសារវិញ្ញាបនបត្របញ្ជាក់បញ្ជិកាប្រភេទថ្នាំកសិកម្ម ឬជីកសិកម្មដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ត្រូវរាយការណ៍ ឬផ្តល់ព័ត៌មានជូនមន្ត្រីអធិការកិច្ច ឬអង្គភាពកសិកម្មមានសមត្ថកិច្ចនៅក្នុងមូលដ្ឋានសាមី អំពីគ្រោះថ្នាក់ ឬផលប៉ះពាល់នៃថ្នាំកសិកម្ម ឬជីកសិកម្មដែលខ្លួនធ្វើការតាំងលក់ សន្និធិសម្រាប់លក់ និងធ្វើការផ្គត់ផ្គង់ចែកចាយ
- ត្រូវរាយការណ៍ជាបន្ទាន់មកអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត ក្នុងករណីមានការសង្ស័យចំពោះអ្នកទិញប្រភេទជីអ៊ុយរ៉េ ឬជីកសិកម្មផ្សេងទៀត ដែលយកទៅកែច្នៃ ឬផលិតជាគ្រឿងផ្ទុះ ឬបង្កឲ្យប៉ះពាល់ដល់សន្តិសុខជាតិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

- ត្រូវប្រកាសអំពីប្រភេទ យថាប្រភេទ បរិមាណថ្នាំកសិកម្ម ឬជីកសិកម្មដែលធ្វើពាណិជ្ជកម្មប្រចាំឆ្នាំ និងត្រូវមានសៀវភៅកំណត់ត្រាពាណិជ្ជកម្មមអនុលោមតាមគំរូសៀវភៅដែលដាក់ឲ្យប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការតាមដាន និងត្រួតពិនិត្យរបស់មន្ត្រីអធិការកិច្ចមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

គំរូសៀវភៅកំណត់ត្រាពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៨៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់កាប់វិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬលិខិតអនុញ្ញាតតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវអនុវត្តលក្ខខណ្ឌ បទបញ្ជា និងរយៈពេលសុពលភាពដែលកំណត់ក្នុងវិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬលិខិតអនុញ្ញាតនោះ ។

ការផ្ទេរសិទ្ធិកាន់កាប់វិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬលិខិតអនុញ្ញាតទៅតតិយជន ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ សិទ្ធិវន្តដែលបានទទួលការកាន់កាប់បន្តត្រូវមានកាតព្វកិច្ចដូចគ្នាក្នុងការអនុវត្តបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ ។

**មាត្រា ៨៤.-**

ក្រុមហ៊ុនដែលនាំចូល លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្ម ឬជីកសិកម្ម និងក្រុមហ៊ុនសេវាកម្មកម្ចាត់សមាសភាពចង្រៃ មានកាតព្វកិច្ចទទួលខុសត្រូវលើសាខារបស់ខ្លួនដែលបានចុះកិច្ចសន្យា និងទទួលយកការផ្គត់ផ្គង់ចែកចាយផលិតផល ឬជាប្រតិបត្តិករកម្ចាត់សមាសភាពចង្រៃនៅតាមរាជធានី ខេត្ត ។

ក្រុមហ៊ុនដែលនាំចូល លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្ម ឬជីកសិកម្មអាចធ្វើការផ្គត់ផ្គង់ចែកចាយចំពោះតែគ្រឹះស្ថានលក់ដុំ លក់រាយ ឬសាខាចំណុះរបស់ខ្លួនដែលកាន់កាប់លិខិតអនុញ្ញាតសម្រាប់ការលក់ដុំលក់រាយ ចេញដោយមន្ទីរកសិកម្មរាជធានី ខេត្តសាមី ស្របតាមច្បាប់នេះ ។

## ផ្នែកទី ២
## សមត្ថភាពវិជ្ជាជីវៈ និងការទទួលស្គាល់

**មាត្រា ៨៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសេវាកម្មកម្ចាត់សមាសភាពចង្រៃ ធ្វើការផ្គត់ផ្គង់ចែកចាយ ឬធ្វើការលក់ដុំលក់រាយថ្នាំកសិកម្ម និងជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជានាសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនដោយត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដោយអនុលោម

តាមកម្មវិធីសិក្សាកំណត់ ដែលជាបុរេលក្ខខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវផ្តល់សេវាកម្មក្នុងការអនុវត្តកម្មវិធីអប់រំសមត្ថភាពវិជ្ជាជីវៈចំពោះពាណិជ្ជករថ្នាំកសិកម្ម ឬជីកសិកម្ម ដែលតម្រូវដោយច្បាប់នេះ ។

**មាត្រា ៨៦.-**

ក្រុមហ៊ុនដែលធ្វើការនាំចូលនាំចេញ ការលាយផ្សំ និងការវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្ម និងជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានបុគ្គលិកបច្ចេកទេសមួយរូប ឬច្រើនរូបដែលមានបរិញ្ញាបត្រក្សេត្រវិទ្យា បរិញ្ញាបត្រឯកទេសពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម ឬមានសញ្ញាបត្រខ្ពស់ជាង ដើម្បីទទួលខុសត្រូវជាអចិន្ត្រៃយ៍លើក្របខ័ណ្ឌបច្ចេកទេសដែលតម្រូវដោយច្បាប់នេះ និងត្រូវមានការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការបញ្ឈប់ ឬការផ្លាស់ប្តូរបុគ្គលិកបច្ចេកទេសប្រចាំការ ត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកថ្មី ។

**មាត្រា ៨៧.-**

មន្ទីរពិសោធន៍ថ្នាំកសិកម្ម ឬជីកសិកម្ម និងអ្នកស្រាវជ្រាវដែលដឹកនាំការសាកល្បងថ្នាំកសិកម្ម ឬជីកសិកម្មលើទីវាលពិសោធន៍ ត្រូវមានការទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

នីតិវិធី និងការតម្រូវសម្រាប់ផ្តល់ការទទួលស្គាល់បុគ្គលិកបច្ចេកទេស អ្នកស្រាវជ្រាវ និងមន្ទីរពិសោធន៍វិភាគថ្នាំកសិកម្ម ឬជីកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី ៣
## កម្រៃសេវាកម្ម

**មាត្រា ៨៨.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំធ្វើសកម្មភាពពាក់ព័ន្ធនឹងថ្នាំកសិកម្ម ឬជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មតាមប្រភេទដូចខាងក្រោម ៖

១- លិខិតអនុញ្ញាតគ្រប់ប្រភេទតាមករណីលិខិតអនុញ្ញាតនីមួយៗ ។

២- ការចុះបញ្ជី ឬការចុះបញ្ជីជាថ្មីតាមយថាប្រភេទថ្នាំកសិកម្ម ឬជីកសិកម្មនីមួយៗ ។

៣- វិភាគសំណាកនៃថ្នាំកសិកម្ម ឬជីកសិកម្មនៅមន្ទីរពិសោធន៍ជាតិកសិកម្ម តាមយថាប្រភេទសារធាតុចិញ្ចឹមនៃជីកសិកម្មនីមួយៗ និងតាមយថាប្រភេទនៃសារធាតុសកម្មនៃថ្នាំកសិកម្មនីមួយៗ ។

៤- ការសាកល្បងជីវប្រសិទ្ធភាពនៃថ្នាំកសិកម្ម ឬជីកសិកម្ម តាមយថាប្រភេទថ្នាំកសិកម្ម ឬជីកសិកម្មនីមួយៗ ។

៥- ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈតាមករណីវគ្គនីមួយៗ ។

៦- ការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកបច្ចេកទេសប្រចាំការ ការទទួលស្គាល់អ្នកស្រាវជ្រាវ ការទទួលស្គាល់កិច្ចប្រតិបត្តិរបស់មន្ទីរពិសោធន៍ថ្នាំកសិកម្ម ឬជីកសិកម្មតាមករណីនីមួយៗ ។

កម្រៃសេវាកម្មតាមប្រភេទនីមួយៗត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៨
## សុពលភាពផ្គត់ផ្គង់ចែកចាយ

### មាត្រា ៨៩.-

ថ្នាំកសិកម្ម ឬជីកសិកម្មគ្រប់ប្រភេទដែលអនុញ្ញាតឲ្យធ្វើការនាំចូល នាំចេញ ឬធ្វើការលាយផ្សំក្នុងគោលបំណងធ្វើពាណិជ្ជកម្ម មានសុពលភាពផ្គត់ផ្គង់ចែកចាយបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលុះត្រាតែផលិតផលទាំងនោះត្រូវបានឆ្លងកាត់ការត្រួតពិនិត្យដើមគ្រាលើការតម្រូវបមាណីយ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូលនាំចេញ ឬធ្វើការលាយផ្សំថ្នាំកសិកម្ម ឬជីកសិកម្មត្រូវធ្វើប្រតិវេទន៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាចាំបាច់ នៅមុនពេលដែលផលិតផលត្រូវបាននាំចូលនាំចេញ ឬត្រូវបានផ្គត់ផ្គង់ចែកចាយ ។

### មាត្រា ៩០.-

នៅពេលថ្នាំកសិកម្ម ឬជីកសិកម្មនាំចូលមកដល់ព្រះរាជាណាចក្រកម្ពុជា អនុលោមតាមលិខិតប្រតិវេទន៍របស់អ្នកកាន់កាប់លិខិតអនុញ្ញាតនាំចូល មន្ត្រីអធិការកិច្ចមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិធ្វើការត្រួតពិនិត្យដើមគ្រា ។

ការត្រួតពិនិត្យដើមគ្រាលើថ្នាំកសិកម្ម ឬជីកសិកម្មដែលធ្វើការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីដើម្បីផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដើម្បីនាំចេញពីព្រះរាជាណាចក្រកម្ពុជា ត្រូវ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បានអនុវត្តនៅពេលដែលម្ចាស់ផលិតផលធ្វើប្រតិវេទន៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ ឬមុនពេលធ្វើការនាំចេញ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិចាត់មន្ត្រីអធិការកិច្ចធ្វើការត្រួតពិនិត្យលើរាល់ប្រតិបត្តិការនាំចូលនាំចេញ ប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្ម ឬជីកសិកម្ម នៅពេលចាំបាច់ ។

**មាត្រា ៩១.-**

រាល់សំណាករបស់ថ្នាំកសិកម្ម ឬជីកសិកម្មដែលត្រូវធ្វើការត្រួតពិនិត្យដើមគ្រា ត្រូវបានដកយកដោយមន្ត្រីអធិការកិច្ចមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើវិភាគផ្ទៀងផ្ទាត់បមាណីយដើម និងត្រួតពិនិត្យលើរាល់ការបំពេញការតម្រូវបមាណីយដែលបានអះអាងនៅពេលស្នើសុំការចុះបញ្ជី ។

**មាត្រា ៩២.-**

នីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៩
## អធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម

**មាត្រា ៩៣.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់តាំងមន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ ។

មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម មានភារកិច្ច និងសិទ្ធិដូចខាងក្រោម :

- ធ្វើការត្រួតពិនិត្យដើមគ្រាលើថ្នាំកសិកម្ម និងជីកសិកម្មនៅមុនពេលផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ
- តាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យជាប្រចាំលើរាល់សកម្មភាពនៅគ្រប់គ្រឹះស្ថានពាក់ព័ន្ធនឹងពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ
- ត្រួតពិនិត្យការដឹកជញ្ជូនថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ
- តម្រូវឲ្យពាណិជ្ជករថ្នាំកសិកម្ម និងជីកសិកម្មផ្តល់ព័ត៌មាន និងបង្ហាញលិខិតអនុញ្ញាតវិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬឯកសារដែលពាក់ព័ន្ធក្នុងសកម្មភាពពាណិជ្ជកម្មរបស់ខ្លួន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

- ចាត់វិធានការហាមឃាត់ជាបណ្តោះអាសន្នចំពោះការផ្គត់ផ្គង់ចែកចាយ ឬការចរាចរលើទីផ្សារនូវប្រភេទថ្នាំកសិកម្មនិងជីកសិកម្មទាំងឡាយណាដែលបានស្រាវជ្រាវ ឃើញភស្តុតាងបង្ហានិភ័យក្នុងផលិតកម្មកសិកម្ម ឬបង្កគ្រោះថ្នាក់ចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន

- ដកយកសំណាកថ្នាំកសិកម្ម ឬជីកសិកម្មដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងការធ្វើវិភាគផ្ទៀងផ្ទាត់បមាណីយ

- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាត វិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬឯកសារដែលពាក់ព័ន្ធ ក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ

- ចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាង

- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៩៤.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មទទួលនីតិសម្បទាឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៩៥.-**

រាល់ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មក្នុងការពិនិត្យបទល្មើស ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មមានសមត្ថកិច្ច អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៩៦.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាស័ក្តិ ។ នៅពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មត្រូវមានលិខិតបញ្ជាបេសកកម្ម ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាស័ក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

**មាត្រា ៩៧.-**

នៅក្នុងដំណើរការអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម ក្នុងករណីមានភស្តុតាងជាក់ស្តែង ឬលទ្ធផលវិភាគផ្ទៀងផ្ទាត់បញ្ជាក់ថាថ្នាំកសិកម្ម ឬជីកសិកម្មណាមួយមានបមាណីយផ្ទុយពីការអះអាងនៅពេលស្នើសុំការចុះបញ្ជី មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មមានសមត្ថកិច្ចមានសិទ្ធិចាត់វិធានការផ្អាកជាបណ្តោះអាសន្នមិនឲ្យផ្គត់ផ្គង់ចែកចាយផលិតផលទាំងនោះ ឬតម្រូវឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលខុសត្រូវលើថ្នាំកសិកម្ម និងជីកសិកម្មនោះប្រមូលបញ្ចូលឃ្លាំងវិញដើម្បីដោះស្រាយតាមនីតិវិធី ។

**មាត្រា ៩៨.-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មមានសមត្ថកិច្ច អាចធ្វើបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃទទួលបណ្តឹង ។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជននោះមានសិទ្ធិធ្វើបណ្តឹងទៅយន្តការផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬទៅតុលាការតាមនីតិវិធី ។

**មាត្រា ៩៩.-**

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ ក្នុងករណីដែលវត្ថុតាងនៃបទល្មើសជាផលិតផលហាមឃាត់ ឬមានគ្រោះថ្នាក់ មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម មានសិទ្ធិស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញាដើម្បីធ្វើការបំផ្លាញចោល ដោយអនុលោមតាមនីតិវិធីជាធរមាន ។

ការចំណាយលើសំណាក និងសេវាកម្មវិភាគសំណាកថ្នាំកសិកម្ម និងជីកសិកម្ម ការចំណាយលើការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងនៅក្នុងដំណើរការអនុវត្តច្បាប់នេះ គឺជាបន្ទុករបស់ម្ចាស់វត្ថុតាងនៃបទល្មើស ។ ករណីអត្តសញ្ញាណម្ចាស់វត្ថុតាងនៃបទល្មើសមិនត្រូវបានស្គាល់ រាល់ការចំណាយជាបន្ទុករបស់រដ្ឋ ។

**មាត្រា ១០០.-**

នីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

**មាត្រា ១០១.-**

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន : ការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតឬការព្យួរវិញ្ញាបនបត្របញ្ជាក់បញ្ជិកា និងលិខិតអនុញ្ញាតគ្រប់ប្រភេទ ការពិន័យអន្តរការណ៍ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ ។

**មាត្រា ១០២.-**

ការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតឬការព្យួរវិញ្ញាបនបត្របញ្ជាក់បញ្ជិកា និងលិខិតអនុញ្ញាតគ្រប់ប្រភេទ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម ។

**មាត្រា ១០៣.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មមានសិទ្ធិពិន័យអន្តរការណ៍លើបទល្មើស ដូចមានចែងក្នុងមាត្រា ១០៦ មាត្រា ១០៧ និងមាត្រា ១០៨ នៃច្បាប់នេះ ។

ការពិន័យអន្តរការណ៍អាចអនុវត្តបានក្នុងករណីជនល្មើសសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរំលត់បណ្តឹងអាជ្ញា ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងនៃបទល្មើសដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី ។

ក្នុងករណីដែលមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវស្នើសុំព្រះរាជអាជ្ញាមានសមត្ថកិច្ច ដើម្បីរឹបអូសវត្ថុតាងនៃបទល្មើសជាសម្បត្តិរដ្ឋ ។ ជនដែលមានប្រយោជន៍ពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាទៅតុលាការរដ្ឋប្បវេណី ។

នីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសដែលមានចែងក្នុងច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ១០៤.-**

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រម ឬសាលដីការបស់តុលាការ ឬប្រាក់បានមកពីលក់វត្ថុតាងដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ត្រូវបង់ចូលថវិកាជាតិ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្ដល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួម ក្នុងករណីបង្ក្រាបបទល្មើសជាក់លាក់ណាមួយដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ១០៥.-**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ព្យួរ ឬដកហូតវិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬលិខិតអនុញ្ញាតពាក់ព័ន្ធ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម :

១- មិនធ្វើរបាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវគ្រោះថ្នាក់ ឬផលប៉ះពាល់ដែលបង្កដោយថ្នាំកសិកម្ម ដែលក្រុមហ៊ុនសាមីបានកាន់កាប់បញ្ជិកា ។

២- ក្រុមហ៊ុនថ្នាំកសិកម្ម ឬម្ចាស់កសិដ្ឋាន ដែលមិនបានផ្ដល់ការបណ្ដុះបណ្ដាលអំពីវិធានសុវត្ថិភាព ការបំពាក់ឧបករណ៍ការពារសុវត្ថិភាពថ្នាំកសិកម្ម និងការអនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាពកម្មករនិយោជិតរបស់ខ្លួន ។

៣- ធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្ម ដោយផ្សាយពាណិជ្ជកម្មផ្ទុយនឹងវិធាន និងបទជៀសវាងសម្រាប់ការផ្សាយពាណិជ្ជកម្ម ដែលកំណត់ក្នុងមាត្រា ៧៧ និងមាត្រា ៧៨ នៃច្បាប់នេះ ។

៤- ផ្ទេរសិទ្ធិកាន់កាប់វិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬលិខិតអនុញ្ញាតពាក់ព័ន្ធក្នុងពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្ម ទៅឲ្យតតិយជនដោយគ្មានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៥- ធ្វើការបោះចោលសំណល់ប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម ល្មើសនឹងវិធានដូចមានចែងក្នុងមាត្រា ៤៣ នៃច្បាប់នេះ ។

**មាត្រា ១០៦.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម :

១- ធ្វើការលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្មគ្រប់ប្រភេទ ដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ ។

២- ធ្វើការលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្មដោយគ្មានបញ្ជីប្រភេទថ្នាំកសិកម្ម ឬជីកសិកម្ម ដែលស្នើសុំលក់ និងគ្មានសក្ខីបត្របញ្ជាក់ប្រភពក្រុមហ៊ុនដែលផ្គត់ផ្គង់ចែកចាយដល់គ្រឹះស្ថានលក់ដុំលក់រាយរបស់ខ្លួន ។

៣- ធ្វើការផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្ម ដល់គ្រឹះស្ថានលក់ដុំលក់រាយ ឬសាខាចំណុះ ដែលគ្មានលិខិតអនុញ្ញាតលក់ដុំលក់រាយស្របតាមច្បាប់នេះ ។

៤- ធ្វើការផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម ឬជីកសិកម្មដោយគ្មានកិច្ចសន្យាធ្វើជាអ្នកផ្គត់ផ្គង់ចែកចាយ ឬជាសាខារបស់ក្រុមហ៊ុនដែលនាំចូល លាយផ្សំ ឬវេចខ្ចប់ជាថ្មីដែលកាន់កាប់លិខិតអនុញ្ញាតស្របតាមច្បាប់នេះ ។

៥- គ្មានបុគ្គលិកបច្ចេកទេសប្រចាំការទទួលខុសត្រូវក្នុងក្រុមហ៊ុនដែលធ្វើការនាំចូល នាំចេញ ការលាយផ្សំ និងការវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្ម និងជីកសិកម្ម ដូចមានចែងក្នុងមាត្រា ៨៦ នៃច្បាប់នេះ ។

៦- មិនអនុវត្តលក្ខខណ្ឌ បទបញ្ជា និងរយៈពេលសុពលភាព ដែលកំណត់នៅក្នុងលិខិតអនុញ្ញាត ឬវិញ្ញាបនបត្របញ្ជាក់បញ្ជិកាគ្រប់ប្រភេទក្នុងពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្ម ។

៧- គ្មានកំណត់ត្រាព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការនៃការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិថ្នាំកសិកម្ម ឬជីកសិកម្ម និងក្នុងការធ្វើសេវាកម្មកម្ចាត់សមាសភាពចង្រៃ ។

៨- មិនធ្វើប្រតិវេទន៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការត្រួតពិនិត្យដើមគ្រាចំពោះថ្នាំកសិកម្ម និងជីកសិកម្មដែលធ្វើការនាំចូលនាំចេញ ឬធ្វើការលាយផ្សំនៅមុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ ។

៩- មិនអនុវត្តកាតព្វកិច្ចជាពាណិជ្ជករថ្នាំកសិកម្ម និងជីកសិកម្ម ដូចមានចែងក្នុងកថាខណ្ឌទី ២ មាត្រា ៨២ នៃច្បាប់នេះ ។

១០- ប្រព្រឹត្តល្មើសនឹងបទហាមឃាត់ណាមួយក្នុងការប្រើប្រាស់ថ្នាំកសិកម្មដូចមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ។

១១- ធ្លាប់បានទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា ១០៥ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ទ្វេដង ឬត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ១០៧.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយក្នុងពាណិជ្ជកម្មជីកសិកម្ម ក្នុងចំណោមអំពើដូចខាងក្រោម :

១- មិនអនុវត្តការតម្រូវបមាណីយសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរសម្រាប់ជីកសិកម្មគ្រប់ប្រភេទ ។

២- ធ្វើការនាំចូលនាំចេញ ឬធ្វើការលាយផ្សំជីកសិកម្ម ដោយគ្មានវិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬមិនបានធ្វើការចុះបញ្ជីជាថ្មីនូវជីកសិកម្មនោះស្របតាមច្បាប់នេះ ។

៣- ធ្វើការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិជីកសិកម្មគ្រប់ប្រភេទ ដោយគ្មានលិខិតអនុញ្ញាត និងគ្មានវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មស្របតាមច្បាប់នេះ ។

៤- ធ្វើការនាំចូល ការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីនូវជីកសិកម្មដើម្បីផ្គត់ផ្គង់ចែកចាយ ដោយគ្មានឯកសារបញ្ជាក់ក្រុមហ៊ុន ឬសាខាដែលចុះកិច្ចសន្យាទទួលយកការផ្គត់ផ្គង់ចែកចាយផលិតផលរបស់ខ្លួន ។

៥- ធ្វើពាណិជ្ជកម្មជីកសិកម្មដែលជាផលិតផលក្រោមបមាណីយ ឬផុតសុពលភាពប្រើប្រាស់ដែលបានកំណត់លើស្លាកសញ្ញាព័ត៌មាន ។

៦- មិនអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយនិងវិធានសុវត្ថិភាពសម្រាប់ប្រតិបត្តិការនៃការលាយផ្សំ ការវេចខ្ចប់ជាថ្មី ឬការធ្វើសន្និធិនូវជីកសិកម្មគ្រប់ប្រភេទ ។

៧- ធ្វើការផ្គត់ផ្គង់ចែកចាយជីកសិកម្មគ្រប់ប្រភេទ ដោយគ្មានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយស្របតាមច្បាប់នេះ ។

៨- ជួល ឬប្រើសេវាកម្ម ឬធ្វើការដឹកជញ្ជូនដោយផ្ទាល់នូវជីកសិកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ដោយល្មើសនឹងលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ៧១ នៃច្បាប់នេះ ។

៩- មិនព្រមបញ្ឈប់ការផ្គត់ផ្គង់ចែកចាយជីកសិកម្ម ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចបញ្ឈប់ ឬផ្អាកជាបណ្ដោះអាសន្នតាមនីតិវិធីនៃច្បាប់នេះ ។

១០- ជួល ឬប្រើសេវាកម្ម ឬធ្វើការផ្សាយពាណិជ្ជកម្មដោយផ្ទាល់អំពីជីកសិកម្មដែលគ្មានការយល់ព្រមលើការចុះបញ្ជី គ្មានការយល់ព្រមលើអត្ថបទផ្សាយពាណិជ្ជកម្មដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុន ឬល្មើសនឹងបទហាមឃាត់សម្រាប់ការផ្សាយពាណិជ្ជកម្មជីកសិកម្ម ដែលបានចែងក្នុងមាត្រា ៧៩ នៃច្បាប់នេះ ។

១១- ប្រព្រឹត្តល្មើសនឹងបទហាមឃាត់ណាមួយក្នុងការធ្វើពាណិជ្ជកម្មជីកសិកម្មដូចមានចែងក្នុងចំណុចទី ៣ និងទី ៤ មាត្រា ៧៤ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ទ្វេដង ឬត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ១០៨.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយក្នុងពាណិជ្ជកម្មថ្នាំកសិកម្ម ក្នុងចំណោមអំពើដូចខាងក្រោម :

១- មិនអនុវត្តការតម្រូវបមាណីយសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរសម្រាប់ថ្នាំកសិកម្មគ្រប់ប្រភេទ ។

២- ធ្វើការនាំចូលនាំចេញ ឬធ្វើការលាយផ្សំថ្នាំកសិកម្ម ដោយគ្មានវិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬមិនបានធ្វើការចុះបញ្ជីជាថ្មីនូវថ្នាំកសិកម្មនោះស្របតាមច្បាប់នេះ ។

៣- ធ្វើការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិថ្នាំកសិកម្មគ្រប់ប្រភេទ ដោយគ្មានលិខិតអនុញ្ញាត និងគ្មានវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្មស្របតាមច្បាប់នេះ ។

៤- ធ្វើការនាំចូល ការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្មដើម្បីផ្គត់ផ្គង់ចែកចាយដោយគ្មានឯកសារបញ្ជាក់ក្រុមហ៊ុន ឬសាខាដែលចុះកិច្ចសន្យាទទួលយកការផ្គត់ផ្គង់ចែកចាយផលិតផលរបស់ខ្លួន ។

៥- ធ្វើពាណិជ្ជកម្មថ្នាំកសិកម្មដែលជាផលិតផលក្រោមបមាណីយ ឬផុតសុពលភាពប្រើប្រាស់ដែលបានកំណត់លើស្លាកសញ្ញាព័ត៌មាន ។

៦- ធ្វើសេវាកម្មកម្ចាត់សមាសភាពចង្រៃដោយប្រើថ្នាំកសិកម្មគ្រប់ប្រភេទ ដែលគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ។

៧- មិនអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយ និងវិធានសុវត្ថិភាពសម្រាប់ប្រតិបត្តិការនៃការលាយផ្សំ ការវេចខ្ចប់ជាថ្មី ឬការធ្វើសន្និធិនូវថ្នាំកសិកម្មគ្រប់ប្រភេទ ឬការធ្វើសេវាកម្មកម្ចាត់សមាសភាពចង្រៃ ។

៨- ធ្វើការផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មគ្រប់ប្រភេទ ដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៩- ជួល ឬប្រើសេវាកម្ម ឬធ្វើការដឹកជញ្ជូនដោយផ្ទាល់នូវថ្នាំកសិកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានបណ្ណគ្រោះអាសន្នដឹកជញ្ជូន និងល្មើសនឹងលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ៣៧ នៃច្បាប់នេះ ។

១០- ជួល ឬប្រើសេវាកម្ម ឬធ្វើការដឹកជញ្ជូនដោយផ្ទាល់នូវថ្នាំកសិកម្មឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ដោយល្មើសនឹងលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ៣៩ នៃច្បាប់នេះ ។

១១- ជួល ឬប្រើសេវាកម្ម ឬធ្វើការផ្សាយពាណិជ្ជកម្មដោយផ្ទាល់អំពីថ្នាំកសិកម្មដែលគ្មានការយល់ព្រមលើការចុះបញ្ជី គ្មានការយល់ព្រមលើអត្ថបទផ្សាយដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុន ឬល្មើសនឹងបទហាមឃាត់សម្រាប់ការផ្សាយពាណិជ្ជកម្មថ្នាំកសិកម្មដូចបានចែងក្នុងមាត្រា ៧៩ នៃច្បាប់នេះ ។

១២- មិនព្រមបញ្ឈប់ការផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចបញ្ឈប់ ឬផ្អាកជាបណ្តោះអាសន្ន តាមនីតិវិធីនៃច្បាប់នេះ ។

១៣- ប្រព្រឹត្តល្មើសនឹងបទហាមឃាត់ណាមួយដូចមានចែងក្នុងចំណុចទី ៣ ទី ៤ ទី ៥ ទី ៦ និងចំណុចទី ៧ មាត្រា ៥០ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ទ្វេដង ឬត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ១០៩.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ខែ ទៅ ០១ (មួយ) ឆ្នាំ និងត្រូវពិន័យជាប្រាក់ចំនួនពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយក្នុងពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្ម ក្នុងចំណោមអំពើដូចខាងក្រោម :

១- ក្លែងបន្លំស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ឬប្រើស្លាកសញ្ញាព័ត៌មានជាភាសាបរទេស ។

២- ក្លែងបន្លំសំបកវេចខ្ចប់ ។

៣- ក្លែងបន្លំឈ្មោះទូទៅ ឬឈ្មោះពាណិជ្ជកម្ម ។

៤- ក្លែងបន្លំសមាសធាតុ ឬមានសមាសធាតុផ្សេងពីការអះអាងនៅពេលស្នើសុំការចុះបញ្ជី ឬជាផលិតផលក្រៅបមាណីយ ។

៥- ក្លែងបន្លំប្រភពដើម ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៦- ក្លែងបន្លំព័ត៌មាន និងទិន្នន័យស្តីពីការតម្រូវបមាណីយនៅក្នុងសំណុំបែបបទសម្រាប់ការស្នើសុំការចុះបញ្ជីថ្នាំកសិកម្មឬជីកសិកម្ម ឬការស្នើសុំលិខិតអនុញ្ញាត និងវិញ្ញាបនបត្រដែលពាក់ព័ន្ធគ្រប់ប្រភេទ ។

**មាត្រា ១១០.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២ (ពីរ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ និងត្រូវពិន័យជាប្រាក់ចំនួនពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយក្នុងពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្ម ក្នុងចំណោមអំពើដូចខាងក្រោម :

១- ធ្វើការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការដឹកជញ្ជូន ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ ឬការធ្វើសេវាកម្មកម្ចាត់សមាសភាពចង្រៃនូវថ្នាំកសិកម្មស្ថិតក្នុងចំណាត់ថ្នាក់ពុលខ្ពស់ដែលហាមឃាត់ក្នុងបញ្ជីថ្នាំកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

២- ធ្វើការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការដឹកជញ្ជូន ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយនូវជីកសិកម្មប្រភេទជំរុញការលូតលាស់របស់រុក្ខជាតិ ឬជំណាំលើសកម្រិតខុសប្រក្រតី ឬលាយផ្សំសារធាតុដែលគ្រោះថ្នាក់ និងហាមឃាត់ ។

៣- ធ្វើការនាំចូលសំណល់ថ្នាំកសិកម្ម សំបកវេចខ្ចប់ថ្នាំកសិកម្មដែលប្រើរួច ឬថ្នាំកសិកម្មចាស់ ។

៤- ធ្វើពាណិជ្ជកម្មឬបោះចោលជីកសិកម្មខូចគុណភាពដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ។

៥- ធ្វើការបោះចោល ការកប់ចោល ការដុតចោល ការចាក់ចូល ឬការបង្ហូរចូលដោយចេតនានូវសំណល់ថ្នាំកសិកម្ម សំបកវេចខ្ចប់ថ្នាំកសិកម្ម ឬថ្នាំកសិកម្មចាស់ទៅក្នុងប្រភពទឹក ឬក្នុងមជ្ឈដ្ឋានផ្សេងទៀតផ្ទុយនឹងបទប្បញ្ញត្តិហាមឃាត់នៃច្បាប់នេះ ។

**មាត្រា ១១១.-**

ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តអំពើណាមួយក្នុងពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្ម ក្នុងចំណោមអំពើដូចខាងក្រោម :

១- ក្លែងលេខបញ្ជិកាថ្នាំកសិកម្ម ឬជីកសិកម្ម ដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២- ក្លែងលទ្ធផលវិភាគ ឬក្លែងលទ្ធផលសាកល្បងជីវប្រសិទ្ធិភាពនៃថ្នាំកសិកម្ម ឬជីកសិកម្ម ។

៣- ក្លែងលិខិតអនុញ្ញាត ឬវិញ្ញាបនបត្របញ្ជាក់បញ្ជិកាក្នុងការធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្ម។

៤- សម្លុតគំរាមចំពោះមន្ត្រីមានសមត្ថកិច្ចនៅក្នុងពេលបំពេញភារកិច្ច ឬក្នុងប្រតិបត្តិការអធិការកិច្ចនិងអនុវត្តច្បាប់ ។

៥- លាក់បំបាំងវត្ថុតាងនៃបទល្មើស និងភស្តុតាងផ្សេងទៀត ដែលត្រូវឃាត់ទុកជាបណ្តោះអាសន្ន ឬត្រូវរឹបអូស ។

៦- ប្រព្រឹត្តល្មើសនឹងចំណុចទី ៥ មាត្រា ៧៤ នៃច្បាប់នេះ ។

**មាត្រា ១១២.-**

នីតិបុគ្គលអាចប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសនៃមាត្រា ១០៩ មាត្រា ១១០ និងមាត្រា ១១១ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ ស្តីពីទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ១១៣.-**

បុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១០៦ មាត្រា ១០៧ មាត្រា ១០៨ មាត្រា ១០៩ មាត្រា ១១០ មាត្រា ១១១ និងមាត្រា ១១២ នៃច្បាប់នេះ ត្រូវបានដកហូត ឬលុបចោលដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវវិញ្ញាបនបត្របញ្ជាក់បញ្ជិកា និងលិខិតអនុញ្ញាតគ្រប់ប្រភេទដែលពាក់ព័ន្ធ ។

ក្នុងករណីបទល្មើសបណ្តាលឲ្យមានផលប៉ះពាល់ ឬមានគ្រោះថ្នាក់ដល់បរិស្ថាន ឬខូចខាតសម្បត្តិសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិធ្វើបណ្តឹងទាមទារសំណងចំពោះបុគ្គលដែលប្រព្រឹត្តបទល្មើស ។ ផលប៉ះពាល់ត្រូវវាយតម្លៃដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬត្រូវមានការចូលរួមវាយតម្លៃដោយតំណាងអន្តរក្រសួងពាក់ព័ន្ធតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ១១៤.-**

វត្ថុតាងនៃបទល្មើសដែលមានចែងក្នុងច្បាប់នេះរួមមាន : ថ្នាំកសិកម្ម ឬជីកសិកម្មដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស និងឧបករណ៍ជំនួយដែលជាសម្ភារបរិក្ខារ និងមធ្យោបាយដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

ការសម្រេចអំពីវត្ថុតាងដែលចាប់យក ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១១៥.-**

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ១០៦ មាត្រា ១០៧ និងមាត្រា ១០៨ ដែលសំណុំរឿង បានបញ្ជូនមកតុលាការ និងបទល្មើសដូចមានចែងក្នុងមាត្រា ១០៩ មាត្រា ១១០ និងមាត្រា ១១១ នៃច្បាប់នេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១- ហាមឃាត់ការប្រកបមុខរបរដែលពាក់ព័ន្ធនឹងថ្នាំកសិកម្ម ឬជីកសិកម្មជាស្ថាពរ ឬសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២- រឹបអូសវត្ថុតាងនៃបទល្មើស ។

៣- បិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

៤- ផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

**មាត្រា ១១៦.-**

មន្ត្រីមានសមត្ថកិច្ចណាដែលរំលោភលើសមត្ថកិច្ចរបស់ខ្លួន ឬប្រើសិទ្ធិអំណាចរារាំងការអនុវត្តច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមាន ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

## ជំពូកទី ១១
## អន្តរប្បញ្ញត្តិ

**មាត្រា ១១៧.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្មគ្រប់ប្រភេទ និងធ្វើសេវាកម្មកម្ចាត់សមាសភាពចង្រៃ ដែលកំពុងដំណើរការក្រោមលិខិតអនុញ្ញាតណាមួយនៅមុនពេលដែលច្បាប់នេះចូលជាធរមាន ត្រូវបំពេញសំណុំបែបបទស្នើសុំលិខិតអនុញ្ញាតឡើងវិញ និងស្នើសុំការចុះបញ្ជីជាថ្មី ដោយអនុលោមតាមការតម្រូវបមាណីយដូចមានចែងក្នុងបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ ក្នុងរយៈពេលមិនលើសពី ១២ (ដប់ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ ។

**មាត្រា ១១៨.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់កាប់លិខិតអនុញ្ញាតសុពលភាពនៅមុនពេលច្បាប់នេះចូលជាធរមាន ហើយនៅសល់សន្និធិ ឬកំពុងតាំងលក់ថ្នាំកសិកម្ម ឬជីកសិកម្មដែលមិនឆ្លើយតបតាមការតម្រូវបែមាណីយ ត្រូវបញ្ចប់ការផ្គត់ផ្គង់ចែកចាយបន្តទៀតនៅក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ ។ ក្នុងរយៈពេលនេះ ថ្នាំកសិកម្ម ឬជីកសិកម្មដែលមានស្លាកសញ្ញាព័ត៌មានជាភាសាបរទេសនៅលើសំបកវេចខ្ចប់ អាចប្រើបរិយាយបណ្ណព័ត៌មានជាភាសាខ្មែរជំនួសជាបណ្តោះអាសន្ន ។

## ជំពូកទី ១២
## អវសានប្បញ្ញត្តិ

**មាត្រា ១១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកម.០១១២.០០២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
**ហត្ថលេខា**
**ច័ន្ទ សារុន**

លេខៈ ៣៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

49/56 P

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការគ្រប់គ្រង
# ថ្នាំកសិកម្មនិងជីកសិកម្ម

## សទ្ទានុក្រម

**១-ការចុះបញ្ជី** សំដៅដល់ដំណើរការវិភាគ ការសាកល្បងជីវប្រសិទ្ធភាព ការទទួលយកនូវឯកសារយថាប្រភេទបច្ចេកទេសនៃប្រភេទថ្នាំកសិកម្ម ឬជីកសិកម្មដែលស្នើសុំការចុះបញ្ជី ការវាយតម្លៃ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជី និងលេខបញ្ជិកាដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះប្រភេទថ្នាំកសិកម្ម ឬជីកសិកម្មនោះ ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ ។ ការចុះបញ្ជីថ្នាំកសិកម្ម ឬជីកសិកម្មអាចអនុវត្តចំពោះផលិតផល សារជាតុសកម្ម ឬវត្ថុធាតុដើមនៃថ្នាំកសិកម្ម ឬជីកសិកម្ម អាស្រ័យតាមការស្នើសុំសម្រាប់គោលបំណងពាណិជ្ជកម្ម ឬធ្វើការលាយផ្សំ ។

**២-ការតម្រូវបមាណីយ** សំដៅដល់កាតព្វកិច្ចដែលត្រូវបានកំណត់ជាផ្លូវការចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលពាក់ព័ន្ធ ដើម្បីអនុវត្តបមាណីយសម្រាប់ថ្នាំកសិកម្មនិងជីកសិកម្ម ដូចមានចែងក្នុងច្បាប់នេះ ។

**៣-ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម** សំដៅដល់ការប្រើប្រាស់ថ្នាំកសិកម្ម ឬជីកសិកម្មក្នុងសកម្មភាពដូចជា : ការតាំងពិព័រណ៍ផ្លូវការ ការធ្វើអំណោយដល់សាធារណៈ វិស័យសិក្សាធិការ វិស័យសុខាភិបាល ការស្រាវជ្រាវ ការប្រើប្រាស់ផ្ទាល់របស់កសិដ្ឋានទោះឯកជន ឬរដ្ឋ និងសម្រាប់តម្រូវការផ្សេងទៀតដែលមិនមែនជាការធ្វើពាណិជ្ជកម្ម ឬចរាចរណ៍លើទីផ្សារ ។

**៤-ការលាយផ្សំ** សំដៅដល់ប្រតិបត្តិការលាយចូលគ្នានូវសមាសធាតុ ឬវត្ថុធាតុដើម ដើម្បីទទួលបានផលិតផល ឬជាទម្រង់ផ្សំនៃថ្នាំកសិកម្ម ឬជីកសិកម្មដែលអាចប្រើប្រាស់បាន និងមានប្រសិទ្ធភាពឆ្លើយតបតាមការតម្រូវបមាណីយដូចមានចែងក្នុងច្បាប់នេះ ។

**៥-ការវេចខ្ចប់ជាថ្មី** សំដៅដល់ការផ្ទេរថ្នាំកសិកម្ម ឬជីកសិកម្មពីសំបកវេចខ្ចប់ដើមទៅក្នុងសំបកវេចខ្ចប់ថ្មីផ្សេងទៀតក្នុងគោលបំណងងាយផ្គត់ផ្គង់ចែកចាយ និងប្រើប្រាស់ដោយមិនធ្វើការផ្លាស់ប្តូរផលិតផល ឬទម្រង់ផ្សំដើមនៃថ្នាំកសិកម្ម ឬជីកសិកម្ម ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**៦-កម្រិតអនុគ្រោះ** សំដៅដល់កម្រិតអតិបរមានៃសំណល់ថ្នាំកសិកម្ម (MRL) ដែលស្ថិតនៅក្នុង ឬនៅលើកសិផល ផលិតផលស្បៀង ឬចំណីសត្វ (គិតជា mg សំណល់ថ្នាំកសិកម្មក្នុងមួយគីឡូក្រាមផលិតផល) ដែលអនុញ្ញាត ឬទទួលស្គាល់ជាផ្លូវការ ។

**៧-កម្មករទិន្ន** សំដៅដល់ឈ្មោះសញ្ញាបត្រជំនាញកសិកម្មកម្រិតបរិញ្ញាបត្រដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**៨-ជីកសិកម្ម** សំដៅដល់អង្គធាតុដែលប្រើប្រាស់ក្នុងដី ឬលើរុក្ខជាតិដោយផ្តល់នូវសារធាតុចិញ្ចឹមមួយ ឬច្រើន ដើម្បីជំរុញនូវបណ្តុះកម្មគីមីដែលជួយទ្រទ្រង់ និងធ្វើឱ្យប្រសើរដល់ការលូតលាស់ ឬទិន្នផលទាំងបរិមាណនិងគុណភាពនៃដំណាំ ។ សារធាតុចិញ្ចឹមរុក្ខជាតិរួមមាន :

- សារធាតុចិញ្ចឹមចម្បង : N, P, K
- សារធាតុចិញ្ចឹមបន្ទាប់បន្សំ : S, Ca, Mg ។ល។
- មីក្រូសារធាតុចិញ្ចឹម : ដែក(Fe) ម៉ង់កាណែស(Mn) បរ(B) ម៉ូលីបដែន (Mo) ទង់ដែង(Cu) សង្កសី(Zn) ក្លរីន(Cl) កូបាល់(Co) ។ល។

ជីកសិកម្ម ត្រូវបានចាត់ថ្នាក់ដូចជា :

១- ជីអសរីរាង្គ ឬជីគីមី (Inorganic fertilizer/chemical fertilizer) ។

២- ជីសរីរាង្គ (Organic fertilizer) ។

៣- ជីជីវសាស្ត្រ (Bio-fertilizer) ។

៤- ជីកែលំអគុណភាពដី (Soil conditioner) ។

៥- ជីវត្ថុធាតុដើម (Raw Materials) ។

**៩-ជីអសរីរាង្គ** សំដៅដល់ជីគីមីដែលមានសារធាតុចិញ្ចឹមចម្បង (NPK) និងផ្តល់ដោយសមាសធាតុអសរីរាង្គ(រ៉ែ) ឬសមាសធាតុសំយោគ(គីមី) ដែលមានទម្រង់រឹងឬរាវ និងមានសារធាតុចិញ្ចឹមសំខាន់យ៉ាងតិចចំនួនមួយមុខ សារធាតុចិញ្ចឹមបន្ទាប់បន្សំ និងមីក្រូសារធាតុចិញ្ចឹម ។ ជីអសរីរាង្គធម្មតាសំដៅដល់ប្រភេទជីអសរីរាង្គមួយចំនួនដែលធ្លាប់បានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបាននិយមប្រើប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ហើយដែលត្រូវបានកំណត់បញ្ជីឈ្មោះដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**១០-ជីសរីរាង្គ** សំដៅដល់ប្រភេទជីដែលមានប្រភពដើមពីផលិតផលរុក្ខជាតិ ឬសត្វដែលឆ្លងកាត់ការបំបែកធាតុតាមរយៈដំណើរការជីវសាស្ត្រ គីមីសាស្ត្រ ឬដំណើរការផ្សេងទៀតដែលធ្វើឱ្យវត្ថុធាតុដើមប្រែក្លាយដូចទម្រង់ដូចដី គ្មានភ្នាក់ងារចម្លងជំងឺ និងរក្សានូវសារធាតុសរីរាង្គមិនតិចជាង ២០% (Organic Matter "OM") និងអាចផ្តល់សារធាតុចិញ្ចឹមដល់រុក្ខជាតិ ឬដំណាំ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**១១-ជីជីវសាស្ត្រ** សំដៅដល់ប្រភេទជីកសិកម្មដែលក្នុងនោះមានសារជាតុសកម្មជីវសាស្ត្រជាមីក្រូសរពាង្គកាយដែលអាចបង្កាំ (Fixation) និងជំរុញសារជាតុសំខាន់ណាមួយដែលមានស្រាប់នៅ ក្នុងបរិយាកាស ឬដី ឬជំរុញការបំបែកជាតុសារជាតុសរីរាង្គនិងសំណល់រុក្ខជាតិ ឬសត្វ ដើម្បីបង្កើតបានជាសារជាតុចិញ្ចឹមសម្រាប់ទ្រទ្រង់ការលូតលាស់របស់រុក្ខជាតិ ឬដំណាំ ។

**១២-ជីវប្រសិទ្ធភាព** សំដៅដល់ទិន្នន័យដែលបានមកពីការសាកល្បងលើប្រភេទថ្នាំកសិកម្ម ឬជីកសិកម្ម ដែលបញ្ជាក់នូវប្រសិទ្ធភាពនៃសារជាតុសកម្មរបស់ប្រភេទថ្នាំកសិកម្ម ឬសារជាតុចិញ្ចឹមនៃជីកសិកម្មណាមួយជាក់លាក់ ។ ទិន្នន័យជីវប្រសិទ្ធភាពដែលអាចទទួលយកសម្រាប់បញ្ជិកាពេញលេញនៃថ្នាំកសិកម្ម ឬជីកសិកម្មត្រូវបានកំណត់ដោយលទ្ធផលនៃការសាកល្បងនៅលើទីវាលពិសោធន៍ក្នុងមួយ ឬ ០២ (ពីរ) រដូវ នៅលើទីតាំងតំបន់តែមួយ ឬតំបន់ផ្សេងគ្នាសម្រាប់ប្រភេទ ឬក្រុមប្រភេទដំណាំជាក់លាក់ដោយអនុវត្តតាមពិធីសារបច្ចេកទេសដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**១៣-ថ្នាំកសិកម្ម** សំដៅដល់ផលិតផលដែលលាយផ្សំដោយសមាសធាតុផ្សំ ឬល្បាយនៃសារជាតុសកម្មនិងសារជាតុនិចល ដែលត្រូវបានចាត់ថ្នាក់ជាក្រុមថ្នាំកសិកម្មគីមី និងក្រុមថ្នាំកសិកម្មជីវសាស្ត្រ និងត្រូវបានប្រើប្រាស់ដើម្បីបង្ក្រាបសមាសភាពចង្រៃរួមមាន ការការពារ ការកម្ចាត់ ការបំផ្លាញ ការទាក់ទាញ ការបណ្តេញ សត្វល្អិតចង្រៃ ប្រភេទតិណជាតិគ្មានប្រយោជន៍ និងធ្វើឲ្យធូរស្រាលជំងឺដំណាំដែលបង្កដោយផ្សិត បាក់តេរី ណេម៉ាតូត និងវីរុស ក្នុងគោលបំណងការពារផលដំណាំ ។ ថ្នាំកសិកម្មក៏ត្រូវបានរាប់បញ្ចូលផងដែរនូវសារជាតុគីមីកសិកម្មដែលជួយជំរុញ ឬសម្រួលដល់មុខងារ សរីរសាស្ត្ររបស់រុក្ខជាតិ ដូចជានិយ័តករការលូតលាស់ ឬជំរុញការលូតលាស់របស់ដំណាំ ការជម្រុះ ស្លឹក មែក ឬជាភ្នាក់ងារធ្វើឱ្យហោលនូវផ្លែឈើ ឬការពារការជ្រុះនូវផ្លែឈើចាស់ជិតដល់ដំណាក់កាល ទុំ ឬជាសារជាតុគីមីកសិកម្មដែលប្រើប្រាស់ចំពោះដំណាំនៅដំណាក់កាលមុន ឬក្រោយប្រមូលផល ។ ផ្អែកតាមមុខសញ្ញាប្រើប្រាស់ថ្នាំកសិកម្មត្រូវបានបែងចែកជាថ្នាំកសិកម្មសម្រាប់ផលិតកម្មកសិកម្ម ឬសួនដំណាំ (Agriculture /Home Garden pesticide) និងថ្នាំកសិកម្មលំនៅឋាន ឬសម្រាប់សុខភាពសាធារណៈ (Household / Public Health pesticide) ។

**១៤-ថ្នាំកសិកម្មគ្រោះថ្នាក់ខ្ពស់** សំដៅដល់ប្រភេទថ្នាំកសិកម្មដែលមានលក្ខណៈដូចជា : មានភាពពុលស្រួចស្រាវ (Acute toxicity) រួមមានចំណាត់ថ្នាក់គ្រោះថ្នាក់ខ្ពស់បំផុត (Ia) និងគ្រោះថ្នាក់ខ្ពស់ (Ib) ដែលចាត់ថ្នាក់ដោយអង្គការសុខភាពពិភពលោក (WHO) មានផលប៉ះពាល់រយៈវែងនៅពេលប្រឈមមានផលប៉ះពាល់ខ្ពស់ដល់បរិស្ថាន (ថ្នាំពុលក្នុងឧបសម្ព័ន្ធ ក នៃអនុសញ្ញា Stockholm) នាំមកនូវឧបទ្ទវហេតុខ្ពស់និងមានផលប៉ះពាល់ត្រឡប់មក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

លើសុខភាពមនុស្សសត្វ និងបរិស្ថាន ( ថ្នាំកសិកម្មស្ថិតក្នុងឧបសម្ព័ន្ធទី ៣ នៃអនុសញ្ញា Rotterdam ) ។

១៥-**ថ្នាំកសិកម្មចាស់** សំដៅដល់ថ្នាំកសិកម្មដែលសល់សន្និធិរយៈពេលវែង ហួសសម័យ និងត្រូវបានហាមឃាត់នាពេលបច្ចុប្បន្នក្នុងការធ្វើពាណិជ្ជកម្ម និងត្រូវគ្រប់គ្រងឲ្យមានសុវត្ថិភាព ។

១៦-**ថ្នាំកសិកម្មប្រភេទថ្មី** សំដៅដល់ថ្នាំកសិកម្មណាដែលមិនធ្លាប់បានទទួលការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសារធាតុសកម្មថ្មី ឬមានសារធាតុសកម្មថ្មីចម្រុះជាមួយសារធាតុសកម្ម ដែលធ្លាប់បានស្នើសុំការចុះបញ្ជីកន្លងមក ។

១៧-**ថ្នាំកសិកម្មស្ថិតក្រោមលក្ខខណ្ឌ** សំដៅដល់ថ្នាំកសិកម្មដែលការប្រើប្រាស់ទាំងអស់ ត្រូវបានហាមឃាត់ជាទូទៅ តាមរយៈប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារសុខភាពមនុស្ស សត្វ និងបរិស្ថាន ប៉ុន្តែអាចអនុញ្ញាតចំពោះការប្រើប្រាស់ជាក់លាក់ណាមួយ ។ ត្រូវបានរាប់បញ្ចូលផងដែរនូវប្រភេទថ្នាំកសិកម្មទាំងឡាយដែលធ្លាប់ ឬកំពុងប្រើប្រាស់ ហើយត្រូវបានបដិសេធការអនុញ្ញាតឲ្យប្រើប្រាស់ដោយតម្រូវឲ្យដកហូតមកវិញពីចរាចរណ៍លើទីផ្សារក្នុងស្រុក ដោយផ្អែកតាមភស្តុតាងទិន្នន័យស្រាវជ្រាវច្បាស់លាស់ដែលបញ្ជាក់ថាការប្រើប្រាស់ប្រភេទថ្នាំកសិកម្មនោះ ពិតជាធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ។

